# ក

# មាតិកា

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 11 ខែ 06 ឆ្នាំ 2003

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ ព្រះរាជក្រឹត្យ

១០-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥៨ ស្ដីពីការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈចំពោះសព ឯកឧត្ដម **ម៉ុល ណារ៉ុ** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រ កម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ២៧០៧

១១-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៥៩ ស្ដីពី និមិត្តសញ្ញា ត្រា សញ្ញាសក្ដិ និងឯកសណ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ២៧០៨

១៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៦៤ ស្ដីពីការបំពាក់គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ជូនសម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលមាន ស្នាដៃ និងវីរភាពដ៏ឧត្តុង្គឧត្ដមក្នុងការធ្វើពលិកម្មដើម្បីការពារជាតិមាតុភូមិ ២៧២៦

១៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៦៥ ស្ដីពីការបំពាក់គ្រឿងឥស្សរិយយស **ការពារជាតិ** ចំនួន ០៦ គ្រឿង គឺ មាស ០២ គ្រឿង ប្រាក់ ០២គ្រឿង និង សំរិទ្ធិ ០២ គ្រឿង ជូនសម្ដេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលមាន ស្នាដៃ និងវីរភាពដ៏ឧត្តុង្គឧត្ដមក្នុងការធ្វើពលិកម្មដើម្បីការពារជាតិមាតុភូមិ ២៧២៧

១៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៦៦ ស្ដីពីការបំពាក់គ្រឿងឥស្សរិយយស **ការពារជាតិ** ជូននាយទាហានជាន់ខ្ពស់ចំនួន០៣រូប ក្នុង មួយរូប១ចំនួន ០៦ គ្រឿង គឺ មាស ០២ គ្រឿង ប្រាក់ ០២គ្រឿង និង សំរិទ្ធ ០២គ្រឿង ដែលមានស្នាដៃនិងវីរភាពដ៏ឧត្តុង្គឧត្ដមក្នុងការធ្វើពលិកម្មដើម្បីការពារជាតិមាតុភូមិៈ

១-សម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា

២-សម្ដេចក្រុមព្រះ **នរោត្ដម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា

៣- សម្ដេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា ២៧២៨

១៥-១០-២០០១ - ព្រះរាជក្រឹត្យ នស/រកត/១០០១/៣៦៧ ស្ដីពីការបំពាក់គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ជូននាយទាហានជាន់ខ្ពស់ចំនួន ០៣រូប ដែលមានស្នាដៃនិងវីរភាពដ៏ឧត្តុង្គឧត្ដមក្នុងការធ្វើពលិកម្មដើម្បីការពារជាតិមាតុភូមិៈ

១-សម្ដេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា

២-សម្ដេចក្រុមព្រះ **នរោត្ដម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា

៣-សម្ដេច **ហេង សំរិន** អនុប្រធានទី១ រដ្ឋសភា ២៧២៩

## II-រាជរដ្ឋាភិបាល

### ១_ អនុក្រឹត្យ


១៥-១០-២០០១ - អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៧៣០

១៥-១០-២០០១ - អនុក្រឹត្យលេខ ១០៤ អនក្រ.បក ស្តីពីការបង្កើតសញ្ញារបស់ក្រសួងមហាផ្ទៃ ២៧៣២

០៩-១០-២០០១ - អនុក្រឹត្យលេខ ៤២៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៣៥

១០-១០-២០០១ - អនុក្រឹត្យលេខ ៤២៧ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៧៣៦

១០-១០-២០០១ - អនុក្រឹត្យលេខ ៤២៨ អនក្រ.តត ស្តីពីការផ្លាស់ប្តូរភារកិច្ចនិងតែងតាំងអភិបាលខ័ណ្ឌនៃរាជធានីភ្នំពេញ ២៧៣៧

១០-១០-២០០១ - អនុក្រឹត្យលេខ ៤២៩ អនក្រ.តត ស្តីពីការផ្លាស់ប្តូរភារកិច្ចនិងតែងតាំងអភិបាលស្រុកនៃខេត្តមណ្ឌលគីរី ២៧៣៨

១០-១០-២០០១ - អនុក្រឹត្យលេខ ៤៣០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៣៩

១១-១០-២០០១ - អនុក្រឹត្យលេខ ៤៣១ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២៧៤០

១១-១០-២០០១ - អនុក្រឹត្យលេខ ៤៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៤២

១១-១០-២០០១ - អនុក្រឹត្យលេខ ៤៣៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៤៦

១១-១០-២០០១ - អនុក្រឹត្យលេខ ៤៣៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២៧៤៨

១១-១០-២០០១ - អនុក្រឹត្យលេខ ៤៣៥ អនក្រ.តត ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យកាល់ម៉ែត ២៧៦៤

១៥-១០-២០០១ - អនុក្រឹត្យលេខ ៤៣៦អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២៧៦៦

១៥-១០-២០០១ - អនុក្រឹត្យលេខ ៤៣៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២៧៦៨


### ២_ សេចក្តីសំរេច


១០-១០-២០០១ - សេចក្តីសំរេចលេខ ៦១ សសរ ស្តីពីការអភិវឌ្ឍន៍គំរោង រៀបចំការផ្គត់ផ្គង់អគ្គីសនីជនបទ និងសាងសង់ខ្សែបណ្តាញជាតិបញ្ជូនអគ្គីសនីភាគខាងត្បូង ២៧៦៩

១១-១០៥-២០០១ - សេចក្តីសំរេចលេខ ៦២ សសរ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសចំរុះទទួលបន្ទុកការអភិវឌ្ឍន៍រួមគ្នាលើធនធានប្រេងកាត នៅក្នុងតំបន់នៃការទាមទារអះអាងដែនសមុទ្រត្រួតគ្នានៃខ្ពង់រាបបាតសមុទ្រ កម្ពុជា- ថៃ ២៧៧១

១១-១០-២០០១ -សេចក្តីសំរេចលេខ ៦៣ សសរ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសំរបសំរួលបរិស្ថានតំបន់ឆ្នេរសមុទ្រ ២៧៧៤

១២-១០-២០០១ - សេចក្តីសំរេចលេខ ៦៤ សសរ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងស្រាវជ្រាវ

# គ

| | | |
|---|---|---|
| | បាតុភាពមិនប្រក្រតីនាំមនុស្សទៅបរទេសនៅក្រសួងទេសចរណ៍ | ២៧៨០ |
| | **១. សេចក្ដីណែនាំ** | |
| ១១-១០-២០០១ | - សេចក្ដីណែនាំលេខ ១១ ស.ណ.ន របស់គណៈបញ្ជាការការពារការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ | ២៧៨២ |
| | **III-ការងារបណ្ដាក្រសួង** | |
| | **១. ធនាគារជាតិ នៃ កម្ពុជា** | |
| ១៥-១០-២០០១ | - ប្រកាសលេខ ធ.៧-០១-១៣៦ ប្រក ស្ដីពីប្រាក់តំកល់ធានាលើដើមទុន | ២៧៨៤ |
| ១៥-១០-២០០១ | - ប្រកាសលេខ ធ.៧-០១-១៣៧ ប្រក ស្ដីពីឥណទានចំពោះសម្ព័ន្ធញាតិ | ២៧៨៧ |
| | **២. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន** | |
| ១១-១០-២០០១ | - ប្រកាសលេខ ៣៧៧ ប្រក សក ស្ដីពីការកំណត់ឱ្យប្រើប្រាស់ជាផ្លូវការនូវបទដ្ឋានបច្ចេកទេស ស្ពាន-ថ្នល់ | ២៧៩១ |
| | **៣. ទីស្ដីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** | |
| ១១-១០-២០០១ | - ប្រកាសលេខ ២៦៧ សកបយ ស្ដីពីការឈប់សំរាកពិសេស | ២៧៩៥ |
| ១១-១០-២០០១ | - ប្រកាសលេខ ២៦៨ សកបយ ស្ដីពីសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន | ២៧៩៧ |
| ១១-១០-២០០១ | - ប្រកាសលេខ ២៦៩ សកបយ ស្ដីពីការបង្កើតសៀវភៅបើកប្រាក់ | ២៨០២ |
| | **៤. ទីស្ដីការរដ្ឋមន្ត្រីក្រសួងផែនការ** | |
| ១០-១០-២០០១ | - ប្រកាសលេខ ១៣៧ ផក .ទទអជ ស្ដីពីការបង្កើតលេខាធិការដ្ឋានសំរាប់គណៈកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា | ២៨០៨ |
| ១០-១០-២០០១ | - ប្រកាសលេខ ១៣៨ ផក .ទទអជ ស្ដីពីការបង្កើតលេខាធិការដ្ឋានសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អនុតំបន់វិសាលភាពទន្លេមេគង្គ | ២៨១១ |

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៥៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

**ជាកិច្ចបច្ឆាមរណៈ**

**ចំពោះសព**

**ឯកឧត្តមឧត្តមសេនីយ៍ឯក ម៉ុល ណារ៉ាល់**

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ព្រះហស្តលេខា

នរោត្តម សីហនុ

គោ: ២៥៤៤ ច.ល

បើឡើងចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] ដាន់

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

## ស្តីពី

## និមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

នស/រកត/១០០១/៣៥៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ ក្រុមប្រឹក្សាធម្មនុញ្ញ

-តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានការឯកភាពពីក្រុមប្រឹក្សាធម្មនុញ្ញក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០០១ ។

**ត្រាស់បង្គាប់**

**ជំពូកទី១**

**អំពីនិមិត្តសញ្ញា**

**មាត្រា ១ .-**

អនុញ្ញាតឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បន្តប្រើប្រាស់និមិត្តសញ្ញាដែលមានរួចហើយ សំរាប់សម្គាល់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២ .-**

និមិត្តសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញ មានរូបព្រះព្រហ្មមានព្រះភ័ក្ត្រ ៤ និង ព្រះហស្ត ៤ កាន់កេតនភណ្ឌ គង់លើបល្ល័ង្ក ។

ព្រះព្រហ្មជានិមិត្តរូបនៃអ្នកបង្កើតលោក ។

ព្រះភ័ក្ត្រព្រះព្រហ្មតំណាងឱ្យព្រហ្មវិហារធម៌ទាំងបួនគឺ ៖ មេត្តា ករុណា មុទិតា និង ឧបេក្ខា ។

- ព្រះហស្តឆ្វេងខាងលើកាន់ផ្កាឈូក : តំណាងការកកើត
- ព្រះហស្តឆ្វេងខាងក្រោមកាន់សាស្ត្រា: តំណាងគម្ពីរ ក្បួន ច្បាប់
- ព្រះហស្តស្តាំខាងលើកាន់ផ្គាំ : តំណាងឱ្យការរំងាប់អារម្មណ៍ ការឧទ្ទិសកុសល ការចំរើនភាវនា រកអំពើល្អ ផ្លូវធម៌ ផ្លូវលោក
- ព្រះហស្តស្តាំខាងក្រោមកាន់ពួចទឹក : តំណាងទឹកអម្រឹតប្រោះព្រំ ឱ្យសុខសប្បាយត្រជាក់ត្រជុំ ឱ្យរស់ ។

មាត្រា ៣.-

គំរូនិមិត្តសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ មានតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ( ដូចក្នុងឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យនេះ ) ។

## ជំពូកទី ២

## អំពីត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ

មាត្រា ៤.-

អនុញ្ញាតឱ្យក្រុមប្រឹក្សាធម្មនុញ្ញ បន្តប្រើប្រាស់ត្រាដែលមានរួចហើយ សំរាប់ប្រថាប់លើឯកសារផ្លូវការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

មាត្រា ៥.-

ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានលក្ខណៈដូចខាងក្រោម ៖

- រង្វង់ខាងក្នុងមាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ
- នៅក្នុងហាមមណ្ឌល :
    - ផ្នែកខាងលើមានចារឹកអក្សរ " **ព្រះរាជាណាចក្រកម្ពុជា** "
    - ផ្នែកខាងក្រោមមានចារឹកអក្សរ " **ក្រុមប្រឹក្សាធម្មនុញ្ញ** "

មាត្រា ៦.-

គំរូត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានតម្កល់ទុកនៅក្រសួងមហាផ្ទៃ ។

មាត្រា ៧.-

ខ្នាត និង គំរូត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានដូចក្នុងឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## អំពីរូបសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញ

**មាត្រា ៨ .-**

បង្កើតរូបសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ សំរាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញប្រើប្រាស់ និង ជូនភ្ញៀវកិត្តិយសរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៩ .-**

រូបសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញមានខ្នាតតូចធ្វើអំពីមាសសំរាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ និង ខ្នាតធំធ្វើអំពីប្រាក់សំរាប់ផ្តល់ជូនភ្ញៀវកិត្តិយសរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ១០ .-**

រូបសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញខ្នាតតូច មានរាងជារង្វង់ពណ៌មាសនៅកណ្តាល ពទ្ធ័ជុំវិញដោយហាមមណ្ឌលពណ៌ខៀវ ។ នៅផ្នែកខាងលើហាមមណ្ឌលមានចារឹកអក្សរខ្មែរ " **ក្រុមប្រឹក្សាធម្មនុញ្ញ** " និង នៅផ្នែកខាងក្រោមមានចារឹកអក្សរអង់គ្លេស " **Constitutional Council** " ។ នៅលើផ្ទៃរង្វង់ពណ៌មាស មាននិមិត្តសញ្ញានៃក្រុម-ប្រឹក្សាធម្មនុញ្ញពណ៌ស ។

រូបសញ្ញា នៃក្រុមប្រឹក្សាធម្មនុញ្ញខ្នាតធំមានរាងជារង្វង់ មាននិមិត្តសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ នៅចំកណ្តាល ។ ផ្នែកខាងលើនៃនិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ មានចារឹកអក្សរខ្មែរ " **ក្រុមប្រឹក្សាធម្មនុញ្ញ** " និង នៅផ្នែកខាងក្រោមមានចារឹកអក្សរអង់គ្លេស " Constitutional Council " ឬ អក្សរបារាំង " Conseil Constitutionnel " ។ រង្វង់នេះព័ទ្ធជុំវិញដោយហាមមណ្ឌល ដែលលំអដោយក្បាច់សន្លឹកភ្ញីទេស ។

**មាត្រា ១១ .-**

រូបសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញទាំងខ្នាតតូច ទាំងខ្នាតធំ មានតម្កល់ទុកនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញ ( ដូចក្នុងឧបសម្ព័ន្ធទី ៣ នៃ ព្រះរាជក្រឹត្យនេះ ) ។

## ជំពូកទី៤
## អំពីសញ្ញាសក្តិ និង ឯកសណ្ឋាន

**មាត្រា ១២ .-**

បង្កើតសញ្ញាសក្តិ និង ឯកសណ្ឋានសំរាប់សម្គាល់ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ១៣ .-**

សញ្ញាសក្តិ រួមមាន សក្តិស្មា សក្តិចុងកអាវ និង សក្តិចុងដៃអាវ ទាំងសងខាង ។

ឯកសណ្ឋាន រួមមាន ឯកសណ្ឋានធំលេខ ១ ឯកសណ្ឋានធំលេខ ២ និងឯកសណ្ឋានធំលេខ ៣ ។

សញ្ញាសក្តិ និង ឯកសណ្ឋាននេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និង ពិធីផ្លូវការផ្សេងៗ ។

## ផ្នែកទី ១
## អំពីសញ្ញាសក្តិ

មាត្រា ១៤ .-

សញ្ញាសក្តិសំរាប់ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកំណត់ដូចតទៅ ៖

**១-សំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**ក-សក្តិស្មា** : មានផ្ទៃកម្ពីពណ៌ខ្មៅ ។ នៅខាងដើមនៃតួសក្តិមានឡេវរូបព្រះសង្ហារពណ៌មាសមួយ ដែលមានអង្កត់ផ្ចិតប្រវែង ១.៨០ សង់ទីម៉ែត្រ ។ បន្ទាប់មកមាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញគង់នៅលើបល្ល័ង្កក្បាច់ត្របកឈូក០៩ សន្លឹកពណ៌មាស ។ នៅផ្នែកខាងមុខនៃតួសក្តិមានតុបតែងដោយក្បាច់ដើមភ្ញីវល្លិ រចនាដោយសន្លឹកពណ៌មាស តំណាងឱ្យដំណាំឧស្សាហកម្ម និង ដំណាំរួមផ្សំនៅកម្ពុជា ។ ឡេវ និមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ និង ក្បាច់ដើមភ្ញីវល្លិ ហ៊ុំព័ទ្ធដោយ ៖

- ខ្សែពួរវេញពណ៌មាសបីខ្សែ
- បន្ទាប់មកមានក្បាច់ជរជាយសន្លឹកភ្ញីទេសពណ៌មាសពីរខ្សែវេញចូលគ្នា និង
- នៅរឹមនៃជាយតួសក្តិ មានខ្សែពួរវេញពណ៌មាសធំមួយខ្សែ ។

ខ្នាតសក្តិស្មាមានរាងចតុកោណព្នាយ ដែលត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

- បាតធំប្រវែង ៥.៥០ សង់ទីម៉ែត្រ
- បាតតូចប្រវែង ៤.៥០ សង់ទីម៉ែត្រ មានរាងកាត់ជ្រុងសងខាង
- បណ្តោយពីបាតតូចដល់បាតធំប្រវែង ១២.៤០ សង់ទីម៉ែត្រ

**ខ-សក្តិចុងកអាវ** : មានផ្ទៃកម្ពីពណ៌ខ្មៅ ។ នៅផ្នែកខាងដើម និង ខាងក្រោមតួសក្តិ មាននិមិត្តសញ្ញាក្រុម-ប្រឹក្សាធម្មនុញ្ញគង់នៅលើបល្ល័ង្កក្បាច់ត្របកឈូក០៩ សន្លឹកពណ៌មាស ។ នៅផ្នែកខាងចុងនៃតួសក្តិមានក្បាច់ដើមភ្ញី-វល្លិ រចនាដោយសន្លឹក ផ្លែ ផ្កា ពណ៌មាស ដែលតំណាងឱ្យផលិតផលដំណាំឧស្សាហកម្ម និង ដំណាំរួមផ្សំនៅកម្ពុជា ។ នៅជ្រុងខាងដើម និង ខាងលើនៃរូបទាំងពីរខាងលើនេះមាន ៖

- ខ្សែពួរវេញពណ៌មាសបីខ្សែ
- បន្ទាប់មកមានក្បាច់ជរជាយសន្លឹកភ្ញីទេសពណ៌មាសពីរខ្សែវេញចូលគ្នា និង
- នៅរឹមនៃជាយតួសក្តិមានខ្សែពួរវេញពណ៌មាសធំមួយខ្សែ ។

ខ្នាតសក្តិចុងកអាវត្រូវបានកំណត់ដូចខាងក្រោមនេះ -

- មានរាងជាប្រលេឡូក្រាម
- បណ្ដោយប្រវែង ៩,៨០ សង់ទីម៉ែត្រ
- ទទឹងប្រវែង ៤,០០ សង់ទីម៉ែត្រ

**គ-សក្តិចុងដៃអាវ** : មានផ្ទៃកម្ទីពណ៌ខ្មៅ ។ នៅផ្នែកខាងក្រៅ និង ខាងក្រោម មាននិមិត្តសញ្ញាក្រុមប្រឹក្សា-ធម្មនុញ្ញ គង់នៅលើបល្ល័ង្កក្បាច់ត្របកឈូក ០៩ សន្លឹកពណ៌មាស និង ទ្រដោយក្បាច់កួរស្រូវពណ៌មាសពីរកោងរាងស្នែងក្របីដែលតំណាងឱ្យការបង្កបង្កើនផលស្រូវនៅកម្ពុជា ។ បន្ទាប់មកមានតុបតែងដោយក្បាច់ដើមភ្ញីវល្លិពីរខ្សែព័ទ្ធគ្នា រចនាដោយសន្លឹក ផ្លែ ផ្កា ដែលតំណាងឱ្យផលិតផលដំណាំឧស្សាហកម្ម និង ដំណាំរួមផ្សំនៅកម្ពុជា ។ នៅពីលើ និង ពីចំហៀងនៃរូបទាំងនេះមាន ៖

- ខ្សែពួរវេញពណ៌មាសបីខ្សែ
- បន្ទាប់មកមានក្បាច់ជរដោយសន្លឹកភ្ញីទេសពណ៌មាសពីរខ្សែវេញចូលគ្នា និង
- នៅរឹមនៃជាយតួសក្តិ មានខ្សែពួរវេញពណ៌មាសធំមួយខ្សែ ។

ខ្នាតសក្តិចុងដៃអាវទាំងសងខាងមានរាងជាចតុកោណព្នាយ ដែលត្រូវបានកំណត់ដូចខាងក្រោមនេះ ៖

-បាតធំប្រវែង ៣៣,៧០ សង់ទីម៉ែត្រ

-បាតតូចប្រវែង ៣១,២០ សង់ទីម៉ែត្រ

-កំពស់ ៩,២០ សង់ទីម៉ែត្រ

*រូបគំនូរសក្តិស្មា សក្តិចុងកអាវ សំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានដូចក្នុងឧបសម្ព័ន្ធទី ៤ និងសក្តិចុងដៃអាវសំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានដូចក្នុងឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យនេះ ។*

**២-សំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ត្រី**

**ក-សក្តិស្មា** : មានលក្ខណៈដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិស្មាសំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិស្មារបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាស្ត្រី មានទំហំ ៨០ % ៨៥ % ឬ ៩១ % នៃសក្តិស្មារបស់បុរស អាស្រ័យលើមាឌ របស់ស្ត្រីជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**ខ-សក្តិចុងកអាវ** : មានលក្ខណៈដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិចុងកអាវសំរាប់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិចុងកអាវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាស្ត្រី មានទទឹងពី ៣ ទៅ ៣,៥០ សង់ទីម៉ែត្រ អាស្រ័យលើមាឌរបស់ស្ត្រីជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

**គ-សក្តិចុងដៃអាវ** : មានលក្ខណៈដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិចុងដៃអាវសំរាប់ប្រធានក្រុមប្រឹក្សាធម្ម-នុញ្ញជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិចុងដៃអាវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជាស្ត្រី អាចមានទំហំទទឹងស្មើនឹង ៧០ ទៅ ៧៥ % នៃសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់ស្ត្រីជាប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ។

៣. សំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ

ក- សក្តិស្មា : មានលក្ខណៈដូចគ្នាគ្រប់ចំណុចនៃសក្តិស្មាសំរាប់ប្រធាន លើកលែងតែខ្សែពួរវេញពណ៌មាសព័ទ្ធជុំវិញខ្សែ និមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ និង ក្បាច់ដើមភ្ញីវល្លិ គឺប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានបីខ្សែ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានតែពីរខ្សែ ។

ខ- សក្តិចុងកអាវ : មានលក្ខណៈដូចគ្នាគ្រប់ចំណុចនៃសក្តិចុងកអាវសំរាប់ប្រធាន លើកលែងតែខ្សែពួរវេញពណ៌មាសព័ទ្ធពីរជ្រុងនៃក្បាច់ភ្ញីទេស និង និមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ គឺប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានបីខ្សែ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានតែពីរខ្សែ ។

គ- សក្តិចុងដៃអាវ : មានលក្ខណៈដូចគ្នាគ្រប់ចំណុចនៃសក្តិចុងដៃអាវសំរាប់ប្រធាន លើកលែងតែខ្សែពួរវេញពណ៌មាសព័ទ្ធបីជ្រុងនៃក្បាច់ភ្ញីទេស និង និមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញ គឺប្រធានក្រុមប្រឹក្សាធម្មនុញ្ញមានបីខ្សែ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានតែពីរខ្សែ ។

*រូបគំនូរសក្តិស្មា សក្តិចុងកអាវ សំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានដូចក្នុងឧបសម្ព័ន្ធទី ៦ និងសក្តិចុងដៃអាវសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញមានដូចក្នុងឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យនេះ។*

៤. សំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ត្រី

ក- សក្តិស្មា: សក្តិស្មាសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាស្ត្រី ដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិស្មាសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិស្មារបស់ស្ត្រី មានទំហំ៨០ % ៨៥ % ឬ ៩០ % នៃសក្តិស្មារបស់បុរស អាស្រ័យលើមាឌ របស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

ខ- សក្តិចុងកអាវ : ដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិចុងកអាវសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិចុងកអាវរបស់ស្ត្រី មានទទឹងពី ៣ ទៅ ៣.៥០ សង់ទីម៉ែត្រ អាស្រ័យលើមាឌរបស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

គ- សក្តិចុងដៃអាវ: ដូចគ្នាគ្រប់ចំណុចទាំងអស់នៃសក្តិចុងដៃអាវសំរាប់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញជាបុរស ។ ដោយឡែកចំពោះខ្នាតសក្តិចុងដៃអាវរបស់ស្ត្រី អាចមានទំហំទទឹងស្មើនឹង ៧០ ទៅ ៧៥ % នៃសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

## ផ្នែកទី ២

## អំពីប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ១៥ .-**

ប្រភេទឯកសណ្ឋានសំរាប់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកំណត់ដូចខាងក្រោម -

១-ឯកសណ្ឋានធំលេខ ១

-សណ្ឋានអាវបុរស

អាវកុដពណ៌ស កត្រង់ កាត់រាងអាវធំគ្មានផែកខ្នង ចុងកអាវទាំងសងខាងមានសក្តិកអាវ មានបន្ទះលើស្មាសំរាប់ដាក់សក្តិមួយគូ ដៃអាវវែង ចុងដៃអាវមានសក្តិ មានហោប៉ៅចោះចំនួន ៤ នៅខាងលើពីរដែលមានគម្របរាងស្លឹកពោធិស្រួចចំកណ្តាល ចោះរន្ធឡេវសំរាប់បិទ មានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិតប្រវែង ១,៨០សង់ទីម៉ែត្រ ហោប៉ៅពីរខាងក្រោមមានគម្របរាងចតុកោណកែង និងគ្មានឡេវ ។ អាវបិទឡេវមុខដោយមានដាក់ឡេវរូបព្រះសង្ហារពណ៌មាស ចំនួន ៧ ដែលឡេវនិមួយៗមានអង្កត់ផ្ចិតប្រវែង ២,៥០ សង់ទីម៉ែត្រ ។

-សណ្ឋានអាវស្ត្រី

អាវជីបរាង ពណ៌ស កត្រង់ ដោយប្រើសាច់ក្រណាត់ដូចឈុតអាវបុរសដែរ គ្មានផែកខ្នង បិទឡេវមុខមានដាក់ឡេវរូបព្រះសង្ហារចំនួន ៥ មានអង្កត់ផ្ចិតប្រវែង ២,៥០ សង់ទីម៉ែត្រ និងមានរាងមូលនៅជាយខាងក្រោម ។ មានបន្ទះលើស្មាសំរាប់ដាក់សក្តិ ចុងកអាវទាំងសងខាងមានសក្តិចុងកអាវ ដៃអាវវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិ ។ អាវមានហោប៉ៅចោះចំនួន ២ នៅខាងក្រោម ដោយមានគម្របរាងចតុកោណកែង និងគ្មានឡេវ ។

-សណ្ឋានសំពត់បុរស និង ស្ត្រី

សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

-សណ្ឋានស្បែកជើងបុរស

ស្បែកជើងឃ្លុបពណ៌ខ្មៅកខ្លី មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅដល់ជង្គង់ ។

-សណ្ឋានស្បែកជើងស្ត្រី

ស្បែកជើងឃ្លុបពណ៌ស កខ្លី គ្មានចងខ្សែ កែងខ្ពស់ ។

រូបគំនូរឯកសណ្ឋានធំលេខ ១ សំរាប់ក្រុមប្រឹក្សាធម្មនុញ្ញ ជាបុរស មានដូចក្នុងឧបសម្ព័ន្ធទី៨ និងសំរាប់ក្រុម-ប្រឹក្សាធម្មនុញ្ញ ជាស្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

ឯកសណ្ឋានធំលេខ ១ នេះ សំរាប់ប្រើក្នុងពិធីស្បថចូលកាន់តំណែង បុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម និងទីកន្លែងផ្សេងៗ ។

ឯកសណ្ឋានប្រពៃណី ត្រូវស្លៀកពាក់ទៅតាមការកំណត់របស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ ឬ តាមការកំណត់របស់ក្រសួងព្រះបរមរាជវាំង ។

២-ឯកសណ្ឋានធំលេខ ២

-សណ្ឋានអាវបុរស និង ស្ត្រី

ដូចគ្នាគ្រប់ចំណុចទាំងអស់នៃឯកសណ្ឋានធំលេខ១ ត្រង់ចំណុចសណ្ឋានអាវបុរស និង សណ្ឋានអាវស្ត្រី ។

-សណ្ឋានខោបុរស

ខោជើងវែងពណ៌ស តចង្កេះ ក្លីបកក្រោយខាងឆ្វេង ២ ខាងស្តាំ ២ ហោប៉ៅចំហៀងនៅសងខាង ហោ-ប៉ៅចោះក្រោយ ១ នៅខាងស្តាំ ។

-សណ្ឋានសំពត់ស្ត្រី

សំពត់អំពីផាមួងពណ៌ខៀវចាស់ ចាក់ជើងខ្សែសយពណ៌ប្លាទីនមាស តាមក្បាច់ជរជើងឯកភាពគ្នា ។

-សណ្ឋានស្បែកជើងបុរស-ស្ត្រី

ស្បែកជើងបុរសឃ្លុបពណ៌ខ្មៅកខ្លី មានចងខ្សែ និងស្រោមជើងពណ៌ខ្មៅធម្មតា ។ ស្បែកជើងស្ត្រីមានសណ្ឋានដូចគ្នានឹងឯកសណ្ឋានធំលេខ ១ ដែរ ។

រូបគំនូរឯកសណ្ឋានធំលេខ ២ សំរាប់ក្រុមប្រឹក្សាធម្មនុញ្ញជាបុរស មានដូចក្នុងឧបសម្ព័ន្ធទី៨ និងសំរាប់ក្រុម-ប្រឹក្សាធម្មនុញ្ញជាស្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

ឯកសណ្ឋានធំលេខ២ នេះសំរាប់ប្រើក្នុងឱកាសទទួលគ្រឿងឥស្សរិយយសនិងពិធីបុណ្យជាតិ និងអន្តរជាតិនានា។

## ៣-ឯកសណ្ឋានធំលេខ ៣

-សណ្ឋានអាវបុរស និង ស្ត្រី

ដូចគ្នាគ្រប់ចំណុចទាំងអស់នៃឯកសណ្ឋានធំលេខ១ ត្រង់ចំណុចសណ្ឋានអាវបុរស និងសណ្ឋានអាវស្ត្រី តែមានពណ៌ខៀវចាស់។

-សណ្ឋានខោបុរស

មានសណ្ឋានដូចគ្នាទាំងអស់ នៃ ឯកសណ្ឋានធំលេខ ២ ខុសត្រង់ពណ៌ខៀវចាស់ ដូចពណ៌អាវ ។

-សណ្ឋានសំពត់ស្ត្រី

សំពត់សំឡយពណ៌ខៀវចាស់ ដោយប្រើសាច់ក្រណាត់ដូចឈុតអាវ ។

-សណ្ឋានស្បែកជើងបុរស និង ស្ត្រី

ដូចគ្នាក្នុងឯកសណ្ឋានធំលេខ ២ ។ ចំណែកស្បែកជើងស្ត្រី ប្រើគ្រប់ឯកសណ្ឋានទាំង ៣ ប្រភេទ ។

រូបគំនូរឯកសណ្ឋានធំលេខ ៣ សំរាប់ក្រុមប្រឹក្សាធម្មនុញ្ញជាបុរស មានដូចក្នុងឧបសម្ព័ន្ធទី ៨ និងសំរាប់ក្រុម-ប្រឹក្សាធម្មនុញ្ញ ជាស្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។

ឯកសណ្ឋានធំលេខ ៣ នេះ សំរាប់ប្រើក្នុងឱកាសទទួលគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិនានា និងបំពេញបេសកកម្មនៅក្រៅប្រទេស ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ១៦ .-**

ការចំណាយសំរាប់ផលិតរូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋានគ្រប់ប្រភេទរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាបន្ទុកក្នុងថវិការបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ១៧ .-**

សញ្ញាសក្តិ និង ឯកសណ្ឋានគ្រប់ប្រភេទរបស់ក្រុមប្រឹក្សាធម្មនុញ្ញមានគំរូរក្សាទុកនៅអគ្គលេខាធិការដ្ឋានក្រុម-ប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ១៨ .-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩ .-**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា

**នរោត្តម សីហនុ**

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

លេខ : ០០១ ចល

**ចំលងចេញពីច្បាប់ដើម**

រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០០១

**អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ**

**ពិត តាំងសាន**

ឧបសម្ព័ន្ធ ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១
ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

# និមិត្តសញ្ញា នៃ ក្រុមប្រឹក្សាធម្មនុញ្ញ



## ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៤៩ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១
## ស្ដីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្ដិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

### ត្រារបស់ក្រុមប្រឹក្សាធម្មនុញ្ញ



- រង្វង់ខាងក្រៅមានអង្កត់ផ្ចិតប្រវែង ៤.៦ cm និង រង្វង់ខាងក្នុងមានអង្កត់ផ្ចិតប្រវែង ៣.២ cm

ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី ខែ ឆ្នាំ២០០១

ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_____

## រូបសញ្ញានៃក្រុមប្រឹក្សាធម្មនុញ្ញ

### ខ្នាតតូច




..................... ២ cm ..................

- រង្វង់ខាងក្រៅមានអង្កត់ផ្ចិតប្រវែង ២ cm និងរង្វង់ពណ៌មាសខាងក្នុង មានអង្កត់ផ្ចិតប្រវែង ១.៦ cm

### ខ្នាតធំ

..................... ១២ cm ..................







- រង្វង់ខាងក្រៅមានអង្កត់ផ្ចិតប្រវែង ១២ cm និងរង្វង់ខាងក្នុងមានអង្កត់ផ្ចិតប្រវែង ១០ cm

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៨ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពី ... សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

សក្តិស្មា





សក្តិចុងកអាវ

**គ្រឿងឥស្សរិយយសក្រុមប្រឹក្សាធម្មនុញ្ញ**

ឧបសម្ព័ន្ធទី៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១

ស្ដីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ



**សក្តិចុងដៃអាវ**



បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______



សក្តិស្នា



សក្តិចុងកអាវ

**សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ**

ឧបសម្ព័ន្ធទី៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១

ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ



សក្តិចុងដៃអាវ



ឧបសម្ព័ន្ធទី៨ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១
ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

សំរាប់ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាបុរស

ឯកសណ្ឋានធំលេខ ១



ឯកសណ្ឋានធំលេខ ២



ឯកសណ្ឋានធំលេខ ៣



ឧបសម្ព័ន្ធទី៩ នៃព្រះរាជក្រឹត្យលេខ នស/រកត/១០០១/៣៥៩ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១
ស្តីពីនិមិត្តសញ្ញា ត្រា រូបសញ្ញា សញ្ញាសក្តិ និង ឯកសណ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ

សំរាប់ប្រធាន និង សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជានារី

ឯកសណ្ឋានជំលេខ ១



ឯកសណ្ឋានជំលេខ ២



ឯកសណ្ឋានជំលេខ ៣



# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៦៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

## ត្រាស់បង្គាប់

**មាត្រា ១ :** បំពាក់គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ជូនសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាដែលមានស្នាដៃនិងវីរភាពដ៏ឧត្តុង្គឧត្តម ក្នុងការធ្វើពលីកម្ម ដើម្បីការពារជាតិមាតុភូមិ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១*

លេខ: ២៥៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាង តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៦៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ការពារជាតិ** ចំនួន ០៦ គ្រឿង គឺមាស ០២ គ្រឿង ប្រាក់ ០២ គ្រឿង និងសំរិទ្ធ ០២ គ្រឿង ជូនសម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាដែលមានស្នាដៃ និងវីរភាពដ៏ឧត្តុង្គឧត្តម ក្នុងការធ្វើពលីកម្ម ដើម្បីការពារជាតិមាតុភូមិ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ២៥៤ច.ល

*រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១*

បានឃើញចំលងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១

**រដ្ឋលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុំ ម៉ាន**

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៦៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ការពារជាតិ** ជូននាយទាហានជាន់ខ្ពស់ចំនួន ០៣ រូប ក្នុងមួយរូបៗ ចំនួន ០៦ គ្រឿង គឺមាស ០២ គ្រឿង ប្រាក់ ០២ គ្រឿង និង សំរិទ្ធ ០២ គ្រឿង ដែលមានស្នាដៃ និងវីរភាពដ៏ឧត្តុង្គឧត្តមក្នុងការធ្វើពលិកម្ម ដើម្បីការពារជាតិមាតុភូមិ ដូចមានរាយព្រះនាម និងនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១-សម្តេច | **ជា ស៊ីម** | អត្តលេខ ០០០០០៥ | ប្រធានព្រឹទ្ធសភា |
| ២-សម្តេចក្រុមព្រះ | **នរោត្តម រណឫទ្ធិ** | អត្តលេខ ០០០០០១ | ព្រះប្រធានរដ្ឋសភា |
| ៣-សម្តេច | **ហេង សំរិន** | អត្តលេខ ០០០០០៤ | អនុប្រធានទី១ រដ្ឋសភា |

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១

លេខៈ ២៥៦ ច.ល

បានយកសេចក្តីចម្លងត្រឹមត្រូវតាមច្បាប់ដើម

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ចាន់

# ព្រះរាជក្រឹត្យ

នស/រកត/១០០១/៣៦៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០៧ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **សេនាជ័យសិទ្ធ** ជូននាយទាហានជាន់ខ្ពស់ចំនួន ០៣ រូប ដែលមានស្នាដៃ និងវីរភាពដ៏ឧត្តុង្គឧត្តមក្នុងការធ្វើពលិកម្ម ដើម្បីការពារជាតិមាតុភូមិ ដូចមានរាយព្រះនាម និង នាមខាងក្រោម :

| | | | |
|---|---|---|---|
| ១-សម្តេច | **ជា ស៊ីម** | អត្តលេខ ០០០០០៥ | ប្រធានព្រឹទ្ធសភា |
| ២-សម្តេចក្រុមព្រះ | **នរោត្តម រណឫទ្ធិ** | អត្តលេខ ០០០០០១ | ព្រះប្រធានរដ្ឋសភា |
| ៣-សម្តេច | **ហេង សំរិន** | អត្តលេខ ០០០០០៤ | អនុប្រធានទី១ រដ្ឋសភា |

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ២៥៧៦.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានថវិកា ចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៣៩២ លានរៀល (បីរយកៅសិបពីរលានរៀលគត់ ) ពីជំពូក ១៣(សកម្មភាពនៃកម្មវិធី ) មកជំពូក ១១ ( ចំណាយ ដំណើរការ រដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ក្រសួង កសិកម្មរុក្ខាប្រមាញ់ និង នេសាទ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកា ចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់ចុះយុទ្ធនាការបង្រ្កាប បទល្មើសព្រៃឈើ នៅភូមិភាគខាងលិចនៃខេត្តកោះកុង ពោធិសាត់ បាត់ដំបង និង ផ្គត់ផ្គង់ប្រេងឥន្ធនៈ ចុះយុទ្ធនាការបង្រ្កាបបទល្មើសព្រៃឈើ និង សួនសត្វភ្នំតាម៉ៅ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១០៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតសញ្ញារបស់ក្រសួងមហាផ្ទៃ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១** : ត្រូវបានបង្កើតសញ្ញារបស់ក្រសួងមហាផ្ទៃ សំរាប់ប្រើប្រាស់ជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** : សញ្ញារបស់ក្រសួងមហាផ្ទៃ ដែលមានរូបភាព និងខ្នាត ដូចក្នុងឧបសម្ព័ន្ធភ្ជាប់ ត្រូវបានកំណត់ដូចតទៅនេះ ÷

- រូបព្រះនារាយណ៍មានដៃបួន ដៃស្តាំខាងលើកាន់ខ្យងស័ង្ខ ដៃស្តាំខាងក្រោមកាន់សៀវភៅ ដៃឆ្វេងខាងលើកាន់កងចក្រ ដៃឆ្វេងខាងក្រោមកាន់ព្រះខ័ន តំណាងអោយភារៈល្អ រក្សា ការពារ កសាង
- មានពណ៌មាស
- មានទទឹង ២ ភាគ ៣ នៃបណ្តោយ
- ពន្លឺកាំរស្មី តំណាងអោយគំនិត ប្រាជ្ញា ស្មារតី
- កងចក្រ ព្រះខ័ន តំណាងអោយសិទ្ធិ អំណាច តួនាទី
- សៀវភៅ តំណាងអោយច្បាប់ លិខិតបទដ្ឋាន
- ខ្យងស័ង្ខ តំណាងអោយភាពត្រជាក់ត្រជុំ សេចក្តីសុខក្សេមក្សាន្ត សុភមង្គល
- ក្បាច់ភ្ញីភ្លើង តំណាងអោយភាពអង់អាចក្លាហាន
- បល្ល័ង្គ តំណាងអោយព្រះធរណី អាជ្ញាធរដែនដី នគរបាលជាតិ

- ភ្ជីក្បាច់ចំរុះ តំណាងអោយអរិយធម៌ វប្បធម៌ ភាពថ្កុំថ្កើងរុងរឿង ។

**មាត្រា ៣** : សញ្ញារបស់ក្រសួងមហាផ្ទៃ សំរាប់ប្រើប្រាស់ជាផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោមនេះ ÷

- ធ្វើត្រា
- ដាក់នៅកន្លែងធ្វើការ
- ធ្វើប្រទីប
- ពាក់នៅលើឯកសណ្ឋានរបស់មន្ត្រីរាជការគ្រប់ខ័ណ្ឌរបស់ក្រសួងមហាផ្ទៃ
- ដាក់នៅលើក្បាលលិខិតផ្លូវការរបស់ក្រសួងមហាផ្ទៃ
- ប្រើប្រាស់ជាផ្លូវការសំរាប់ក្រសួងមហាផ្ទៃ ក្នុងករណីផ្សេងៗទៀត ។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ-កាលប្បវត្តិ*

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១០៤ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១**

**ស្តីពីសញ្ញាក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**



# សញ្ញាក្រសួងមហាផ្ទៃ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

## សំរេច

**មាត្រា ១** : ត្រូវបានតែងតាំងលោក ស្រី សួន ជាប្រធាននាយកដ្ឋានបុគ្គលិក នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ_កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤២៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សារំសាយទ័ព

## ស ំ រ េ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម HELMUT OHLRAUN ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលបានខិតខំជំរុញក្នុងការផ្តល់ជំនួយថវិកាជូនដល់រាជរដ្ឋាភិបាលកម្ពុជា សំរាប់កម្មវិធីរំសាយកងកម្លាំងប្រដាប់អាវុធ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានក្រុមប្រឹក្សារំសាយទ័ព ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ.ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៨៩៥ អនក្រ.បក

## អនុក្រឹត្យ

### ស្ដីពី

### ការផ្លាស់ប្ដូរភារកិច្ច និងតែងតាំងអភិបាលខ័ណ្ឌ នៃរាជធានីភ្នំពេញ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១** : ត្រូវបានផ្លាស់ប្ដូរភារកិច្ចលោក សាមុត ធឿន អភិបាលខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ អោយមកបំរើការងារនៅទីស្ដីការក្រសួងមហាផ្ទៃ ដោយរក្សាឋានៈដដែល ។

**មាត្រា ២** : ត្រូវបានតែងតាំងលោក ជប ខន អភិបាលរងខ័ណ្ឌចំការមន ជាអភិបាលខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

**មាត្រា ៣** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៤៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្លាស់ប្តូរភារកិច្ច និងតែងតាំងអភិបាលស្រុក នៃខេត្តមណ្ឌលគិរី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ : ត្រូវបានផ្លាស់ប្តូរភារកិច្ចលោក អាង ទីវ អភិបាលស្រុកពេជ្រដា ខេត្តមណ្ឌលគិរី អោយមកបំរើការងារនៅសាលាខេត្តមណ្ឌលគិរីវិញ ដោយរក្សាប្រាក់បៀវត្សនៅដដែល។

មាត្រា ២ : ត្រូវបានតែងតាំងលោក មើល សឿន អភិបាលរងស្រុកសែនមនោរម្យ ជាអភិបាលស្រុកពេជ្រដា ខេត្តមណ្ឌលគិរី ។

មាត្រា ៣ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និង មាត្រា ២ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី [illegible] ខែ តុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៣០ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

  បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

### សម្រេច

**មាត្រា ១:** ត្រូវបានតែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ដូចមានរាយនាមខាងក្រោម :

១-លោក **ស៊ឹម សុវណ្ណរិទ្ធិ** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលកិច្ចការទូទៅ

២-លោក **សុខ ថន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧១ អនក្រ - ភក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសអោយប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា១:** ត្រូវបានប្រគល់មេដាយសហមេត្រី " **ថ្នាក់សេនា** " ជូននាយនគរបាលក្នុងបញ្ជាការដ្ឋានអង្គរក្សក្រសួងនគរបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ចំនួន ១២ រូប ដែលមានស្នាដៃល្អ ក្នុងការបង្ហឹកជំនាញការពារថ្នាក់ដឹកនាំជាន់ខ្ពស់ដល់នាយនគរបាល និងពលនគរបាល ក្នុងកងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន ដូចមានរាយនាមខាងក្រោម ÷

១-លោកវរសេនីយ៍ឯក **ឡេ វ៉ាន់គិញ** ( LE VAN KINH ) មេបញ្ជាការ

២-លោកវរសេនីយ៍ឯក **ផាម កុកហុង** ( PHAM QUOC HUNG ) មេបញ្ជាការរង

៣-លោកវរសេនីយ៍ឯក **ទ្រិញ ស៊ិនទ្រឿង** ( TRINH XUAN TRUONG ) មេបញ្ជាការរង

| | | | | |
|---|---|---|---|---|
| ៤-លោកវរសេនីយ៍ឯកបំរុង | វ៉ូ | ស៊្វនសិញ | ( VU XUAN SINH ) | មេបញ្ជាការរង |
| ៥-លោកវរសេនីយ៍ឯកបំរុង | ង្វៀន | ធីឡាន | ( NGUYEN THI LAN ) | គណៈគ្រប់គ្រងវគ្គ |
| ៦-លោកវរសេនីយ៍ឯកបំរុង | ង្វៀន | ឃីគឿន | ( NGUYEN QUY CUONG ) | គ្រូបង្រៀន |
| ៧-លោកវរសេនីយ៍ទោ | ដាំង | ត្រុងហ៊ី | ( DANG TRONG HUY ) | គណៈគ្រប់គ្រងវគ្គ |
| ៨-លោកវរសេនីយ៍ទោ | ង្វៀន | តៀនអាម | ( NGUYEN TIEN AM ) | គណៈគ្រប់គ្រងវគ្គ |
| ៩-លោកវរសេនីយ៍ទោ | ង្វៀន | ហ៊ីវក្វាង | ( NGUYEN HUU QUANG ) | គណៈគ្រប់គ្រងវគ្គ |
| ១០-លោកវរសេនីយ៍ទោ | ហោ | ត្រុងថាំង | ( HO TRONG THANG ) | គ្រូបង្រៀន |
| ១១-លោកវរសេនីយ៍ត្រី | ដាំង | ឌិញក្វាង | ( DANG DINH QUANG ) | គណៈគ្រប់គ្រងវគ្គ |
| ១២-លោកវរសេនីយ៍ត្រី | ផាម | ក្វាងដាត | ( PHAM QUANG DAT ) | គណៈគ្រប់គ្រងវគ្គ |

**មាត្រា២** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តន៍អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ...១១...... ខែ តុលា... ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួងនគរបាលសាធារណរដ្ឋសង្គមនិយមវៀតណាម
- ដូចក្នុងមាត្រា១ និងមាត្រា២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៣៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## សំ រេ ច

មាត្រា ១ : ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ប្រគេនព្រះសង្ឃ និង ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវត្តទួរ៉ុ និង វត្តចន្ទនារាមទ្រាវស នៅស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ដូចមាននាយព្រះនាម និង នាមខាងក្រោមនេះ ÷

ក-មេដាយមាសស្ថាបនាជាតិ :

| | | | | |
|---|---|---|---|---|
| ១-ព្រះសាសនៈសំវរៈ | អំ លឹមហេង | | | បច្ច័យ១១.៣០០ USD |
| ២-ព្រះគ្រូ | ជា ឆោម | | សហរដ្ឋ | បច្ច័យ១១.២០០ USD |
| ៣-លោក | ខែក សារិ | អ្នកស្រី ពន់ ទួច | សហរដ្ឋ | ថវិកា ១៦.១៨៨ USD |
| ៤-លោក | អ៊ុត រឿន | អ្នកស្រី សរ ជាវ៉ាទី | | ថវិកា ១៤.៧៦៩ USD |
| ៥-លោក | ហ៊ិន អៀ | អ្នកស្រី ឡុង ខាន់ឌី | | ថវិកា ១២.៣៦៤ USD |
| ៦-លោក | ចាន់ ឌីន | | សហរដ្ឋ | ថវិកា ១០.៧៧៦ USD |
| ៧-លោក | លន់ សុធី | អ្នកស្រី សេខ ជាលីន | | ថវិកា ១០.០០០ USD |

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | ង៉ាត សារម៉ឿន | | សហរដ្ឋ | ថវិកា ៩.៣៨៦ USD |
| ២-លោក | យង់ ភៅ | អ្នកស្រី ពីងសារឿន | សហរដ្ឋ | ថវិកា ៥.០០០ USD |
| ៣-លោក | ឈឹម ឆន | អ្នកស្រី ស៊ី នួន | សហរដ្ឋ | ថវិកា ៥.០០០ USD |
| ៤-លោក | កេត គេករស្រេង | អ្នកស្រី កី គឹមហួយ | សហរដ្ឋ | ថវិកា ៥.០០០ USD |

គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | ផ្លឹង ម៉ុនធ្បុង | | ប្រទេសថៃ | បច្ច័យ១០.៤០០.០០០៛ |
| ២-ព្រះតេជគុណ | ផន ឈួន | | សហរដ្ឋ | បច្ច័យ ១.០០០ USD |
| ៣-លោក | ផាន ញឹម | អ្នកស្រី ជឹម រិន | សហរដ្ឋ | ថវិកា ៣.៧៤០ USD |
| ៤-លោក | អ៊ុក កុសល | លោក អ៊ុក សំអួន | សហរដ្ឋ | ថវិកា ៣.៥២១USD |
| ៥-ឧបាសិកា | ម៉ារឌី ប្រាក់ | | សហរដ្ឋ | ថវិកា ២.៩៥០ USD |
| ៦-លោកយាយ | ជា ឡុក | | ស្រីសន្ធរ | ថវិកា៦.៥០០.០០០៛ |
| ៧-ឯកឧត្តម | ឆ្បាយ ព្រហស្ត | | ភ្នំពេញ | ថវិកា៦.០០០.០០០៛ |
| ៨-លោក | ជា កំផាន | អ្នកស្រី សុខ ហួយ | ភ្នំពេញ | ថវិកា ៣០០ USD និង ៥.៤២០.០០០៛ |
| ៩-លោកតា | ទេីយ កោះ | លោកយាយ យូ ង៉ាន់ | សហរដ្ឋ | ថវិកា ២.២១៩ USD |
| ១០-ឧបាសិកា | ឌួន យ៉ាន | | សហរដ្ឋ | ថវិកា ២.១៨៣ USD |
| ១១-លោក | ចាន់ ផល្លី | អ្នកស្រី សំ សុខន | ភ្នំពេញ | ថវិកា ២.១៦០ USD |
| ១២-លោកយាយ | កែវ យ៉ាត | | សហរដ្ឋ | ថវិកា ២.១៥៥ USD |
| ១៣-លោក | ម៉ុន ណារ៉េតថ័យនិងលោក ឌុល សុមាលី | | សហរដ្ឋ | ថវិកា ២.១២០ USD |
| ១៤-លោកយាយ | អាន | | ស្រីសន្ធរ | ថវិកា ១.០០០ USD និង ១.២៣០.០០០៛ |
| ១៥-លោក | ធ្បុង លឹម | អ្នកស្រី ប៉ោក ផាន | សហរដ្ឋ | ថវិកា ២.១១១ USD |
| ១៦-លោក | ជុំ គេន | អ្នកស្រី ឆាយ រុំ | សហរដ្ឋ | ថវិកា ២.០៨០ USD |
| ១៧-លោក | គឹម គុណា | អ្នកស្រី ប្រាក់ សុនី | សហរដ្ឋ | ថវិកា ២.០២០ USD |
| ១៨-លោក | គាន់ បញ្ញាឧុច | អ្នកស្រី លីន សុផា | ភ្នំពេញ | ថវិកា ២.០០០ USD |
| ១៩-លោកយាយ | ខៀវ ឈុំ | | សហរដ្ឋ | ថវិកា ១.៩៤០ USD |
| ២០-លោកតា | ថន ឌួន | លោកយាយ កែវ ហុង | សហរដ្ឋ | ថវិកា ១.៩៤០ USD |
| ២១-អ្នកស្រី | ដេវេល ស៊ីនួន | | សហរដ្ឋ | ថវិកា ១.៩២០ USD |
| ២២-លោក | លី វឿន | អ្នកស្រី ហេង ញ៉ | សហរដ្ឋ | ថវិកា ១.៨៩៦ USD |
| ២៣-ឧកញ៉ា | ធ្បូច ហ៊ីង | អ្នកស្រី ណាល់សុខអៀន | ភ្នំពេញ | ថវិកា ១.៨០០ USD |
| ២៤-ឧបាសិកា | គិះ វឿន | | សហរដ្ឋ | ថវិកា ១.៧៦៤ USD |

| | | | | | |
|---|---|---|---|---|---|
| ២៥-លោក | ថន | ធួន | អ្នកស្រី កែវ ហុង | សហរដ្ឋ | ថវិកា ១.៧៥៤ USD |
| ២៦-លោក | ពេជ្រ | សារីឆ្និ | អ្នកស្រី ម៉ៅ យ៉ៅ | សហរដ្ឋ | ថវិកា ១.៧០២ USD |
| ២៧-លោក | ឈាង | ម៉េង | អ្នកស្រី មុី លី | ភ្នំពេញ | ថវិកា ១.៥៩៧ USD |
| ២៨-លោកតា | ឧង់ | គីក | លោកយាយ ឌូ ហ៊ាង | សហរដ្ឋ | ថវិកា ១.៥០០ USD |
| ២៩-លោក | សុ | ផុន | អ្នកស្រី ឌា ហាន | សហរដ្ឋ | ថវិកា ១.៤៨៥ USD |
| ៣០-ឧបាសិកា | ឈាម | ផល | | សហរដ្ឋ | ថវិកា ១.៤៨០ USD |
| ៣១-លោក | នេព | សារឿន | អ្នកស្រី យី គីមលី | ភ្នំពេញ | ថវិកា ១.៣៧០ USD |
| ៣២-ឧបាសិកា | ឡុង | ឡាន | | សហរដ្ឋ | ថវិកា១.១៣៣ USD |
| ៣៣-លោក | សែម | សំណាង | អ្នកស្រី សៀង ផល្លី | សហរដ្ឋ | ថវិកា១.១៣៣ USD |
| ៣៤-លោក | សឿន | | អ្នកស្រី ប៊ុណ្ណារី | សហរដ្ឋ | ថវិកា ១.៣១៨ USD |
| ៣៥-លោក | គេង | ឡាក់ហេង | អ្នកស្រី ថោង ពេង | ព្រៃពោធិ | ថវិកា ១.២៧៤ USD |
| ៣៦-លោក | គឹម | ម៉ៅ | អ្នកស្រី យូ ពេញ | សហរដ្ឋ | ថវិកា ១.២២០ USD |
| ៣៧-ឯកឧត្តម | លូ | គីមឈន់ | លោកជំទាវ ថ្វា គីមពៅ | ក្រុងព្រះសីហនុ | ថវិកា១.២០០ USD |
| ៣៨-ឧបាសិកា | សំ | យ៉ិន | | សហរដ្ឋ | ថវិកា ១.១៨៣ USD |
| ៣៩-លោកយាយ | សន | ម៉ារីន | | សហរដ្ឋ | ថវិកា ១.១៣០ USD |
| ៤០-លោកអាចារ្យ | ហេង | ស៊ឹម | | សហរដ្ឋ | ថវិកា ១.១២០ USD |
| ៤១-លោក | ជ័យ | ផេង | អ្នកស្រី ភាព ហៀក | ភ្នំពេញ | ថវិកា ១.១០៧ USD |
| ៤២-លោក | ឡេ | មឿន | អ្នកស្រី ម៉ិល លឿន | សហរដ្ឋ | ថវិកា ១.១០០USD |
| ៤៣-ឧបាសិកា | ស៊ូ | ឈឿនប៊ិច | | សហរដ្ឋ | ថវិកា ១.០៥៦ USD |
| ៤៤-ឧបាសិកា | រ៉ុី | មូល | | សហរដ្ឋ | ថវិកា ១.០៣៩ USD |
| ៤៥-លោក | ហួត | ធនទញ្ញ | អ្នកស្រី ឆាយ ស៊ីថា | សហរដ្ឋ | ថវិកា ១.០៣០ USD |
| ៤៦-លោក | យី | ផុន | អ្នកស្រី ជៅ៉ក សិន | សហរដ្ឋ | ថវិកា ១.០២៩ USD |
| ៤៧-ឧបាសិកា | ហែម | សូត្រ | | ភ្នំពេញ | ថវិកា ១.០០៤ USD |
| ៤៨-លោកស្រី | ថ្លាង | មិច | | ភ្នំពេញ | ថវិកា ១.០០០ USD |
| ៤៩-ឧបាសិកា | ផាន | ហ៊ិន | | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥០-លោក | សោម | ភា | អ្នកស្រី អ៊ុំ សុភន់ | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥១-លោក | ប៊ិន | សុខហេង | អ្នកស្រី លេម រ៉ា | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥២-ឧបាសិកា | រ៉ុ | គុំ | | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥៣-ឧបាសិកា | ខួន | សយ | | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥៤-លោក | ឡុង | លន | អ្នកស្រី អ៊ុំ សុខ | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥៥-ឧបាសិកា | នេត | យ៉ាន់ | | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥៦-លោក | ធួន | សំអាន | អ្នកស្រី កែវ សុនី | ភ្នំពេញ | ថវិកា ១.០០០ USD |

| | | | | | |
|---|---|---|---|---|---|
| ៥៧-ឧបាសិកា | ទុយ | ហ៊ាង | | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥៨-លោក | ឌិត | សំណាង | អ្នកស្រី យន់ គីមហួយ | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៥៩-លោក | លាង | ឃុន | អ្នកស្រី តែ សុខណ្ណី | ភ្នំពេញ | ថវិកា ១.០០០ USD |
| ៦០-ឧបាសិកា | សៅ | លាប់ | | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៦១-លោក | ធី | ឌឹម | | ភូមិទ្រារស | ថវិកា ១.០០០ USD |
| ៦២-លោក | ច្រឹង | ម៉ែ | | ភូមិទ្រារស | ថវិកា ១.០០០ USD |
| ៦៣-លោក | អៀម | អៀត | | ភូមិទ្រារស | ថវិកា ១.០០០ USD |
| ៦៤-លោក | ជួន | ជឹម | | ភូមិទ្រារស | ថវិកា ១.០០០ USD |
| ៦៥-លោក | ភី | យ៉េន | | ភូមិទ្រារស | ថវិកា ១.០០០ USD |
| ៦៦-លោក | អឹម | ណាន | | ភូមិទ្រារស | ថវិកា ១.០០០ USD |
| ៦៧-លោក | ឈុំ | ហ៊ុន | អ្នកស្រី ប៊ូ កែវ | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៦៨-លោកស្រី | អេង | ហួយ | | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៦៩-លោក | ឌិ | សំអាត | អ្នកស្រី ប៉េង សៀងអ៊ាន | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៧០-លោក | លន់ | ចិរ្ទុ | អ្នកស្រី សួន គីមហុង | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៧១-លោក | លន់ | ចិរៈ | | សហរដ្ឋ | ថវិកា ១.០០០ USD |
| ៧២-លោក | លន់ | ចិបិត្រ | | សហរដ្ឋ | ថវិកា ១.០០០ [illegible] |
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ-បក ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងបរិស្ថាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

# សំរេច

## ប្រការ ១.-

បង្កើតគណៈកម្មាធិការជាតិសំរបសំរួលបរិស្ថានតំបន់ឆ្នេរសមុទ្រ ដែលហៅថា **គ.ជ.ស.ឆ** ដើម្បីសំរបសំរួលការងារគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ ការពារបរិស្ថាន និងធនធានធម្មជាតិនៅតំបន់ឆ្នេរសមុទ្រ ក្នុងទិសដៅលើកកំពស់ការរស់នៅ ជីវភាពរបស់ប្រជាជនដែលរស់នៅក្នុងតំបន់ឆ្នេរសមុទ្រ តាមរយៈការប្រើប្រាស់ និងការអភិវឌ្ឍន៍តំបន់ឆ្នេរប្រកបដោយនិរន្តរភាពនៅកម្ពុជា ។

## ប្រការ ២.-

តំបន់ឆ្នេរសមុទ្ររួមមាន : ខេត្តកំពត ខេត្តកោះកុង ក្រុងព្រះសីហនុ និងក្រុងកែប ដោយរួមបញ្ចូលបូរណភាពដែនសមុទ្រ ដែលលាតសន្ធឹងដល់ព្រំដែនតំបន់សេដ្ឋកិច្ចផ្តាច់មុខ (EEZ) របស់ព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ៣.-

**គ.ជ.ស.ឆ** មានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងបរិស្ថាន | | ប្រធាន |
| ២ - | រដ្ឋលេខាធិការក្រសួងបរិស្ថាន | ១រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣ - | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១រូប | អនុប្រធាន |
| ៤ - | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ១រូប | អនុប្រធាន |
| ៥ - | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | ១រូប | សមាជិក |
| ៦ - | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ១រូប | សមាជិក |
| ៧ - | អនុរដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ១រូប | សមាជិក |
| ៨- | អនុរដ្ឋលេខាធិការក្រសួងផែនការ | ១រូប | សមាជិក |
| ៩ - | អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | ១រូប | សមាជិក |
| ១០- | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ១រូប | សមាជិក |
| ១១ - | អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | ១រូប | សមាជិក |
| ១២ - | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ១រូប | សមាជិក |
| ១៣ - | អនុរដ្ឋលេខាធិការក្រសួងការពារជាតិ | ១រូប | សមាជិក |

| | | | |
|---|---|---|---|
| ១៤ - | អគ្គលេខាធិការអាជ្ញាធរជាតិប្រេងកាត | | សមាជិក |
| ១៥ - | អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១រូប | សមាជិក |
| ១៦ - | អភិបាលខេត្តកំពត | | សមាជិក |
| ១៧- | ប្រតិភូរាជរដ្ឋាភិបាលក្រុងកែប | | សមាជិក |
| ១៨ - | អភិបាលក្រុងព្រះសីហនុ | | សមាជិក |
| ១៩ - | អភិបាលខេត្តកោះកុង | | សមាជិក |

**ប្រការ ៤.-**

**គ.ជ.ស.ឆ** មានតួនាទី និងភារៈកិច្ចដូចខាងក្រោម :

- សំរបសំរួលជាមួយស្ថាប័នជាតិ តំបន់ និងអ្នកផ្តល់ជំនួយ ដើម្បីដោះស្រាយបញ្ហាផ្សេងៗនៅតំបន់ឆ្នេរសមុទ្រ
- ពិនិត្យ និងផ្តល់យោបល់ជូនស្ថាប័នរាជរដ្ឋាភិបាល ដោយតំរង់ទិសគោលនយោបាយ ផែនការ ក្របខ័ណ្ឌច្បាប់ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងតំបន់ឆ្នេរសមុទ្រ អោយស្របទៅនឹងអាទិភាពអភិវឌ្ឍន៍ជាតិ អនុសញ្ញា និងច្បាប់អន្តរ ជាតិផ្សេងៗ ដែលទាក់ទងក្នុងការគ្រប់គ្រងតំបន់ឆ្នេរ
- រៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីសកម្មភាព និងលទ្ធផល ព្រមទាំងផ្តល់យោបល់ជាអនុសាសន៍នានា ដើម្បីផ្ញើជូនរាជរដ្ឋាភិបាល
- ផ្តល់យោបល់ និងណែនាំដល់ការអនុវត្តន៍គ្រប់គំរោងតំបន់ឆ្នេរសមុទ្រ
- ស្វែងរកជំនួយបច្ចេកទេស និងថវិកា សំរាប់ទ្រទ្រង់ដល់ដំណើរការរបស់ **គ.ជ.ស.ឆ**
- ទទួលភារៈកិច្ចផ្សេងៗទៀតតាមសំណូមពររបស់រាជរដ្ឋាភិបាល ។

**ប្រការ ៥.-**

**គ.ជ.ស.ឆ** ប្រើប្រាស់ផ្នែកសំរបសំរួលតំបន់ឆ្នេរសមុទ្រនៃក្រសួងបរិស្ថាន ជាលេខាធិការដ្ឋានដែលមានទីតាំងនៅក្នុងក្រសួងបរិស្ថាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

**គ.ជ.ស.ឆ** អាចបង្កើតក្រុមបច្ចេកទេសជាតិ ដែលមានសមាសភាពជាមន្ត្រីមានក្របខ័ណ្ឌរដ្ឋ ជាជំនួយការដើម្បីអនុវត្តតាមតំរូវការ ភារៈកិច្ច ដូចមានចែងក្នុងមាត្រា ៤ នៃសេចក្តីសំរេចនេះ ។

**គ.ជ.ស.ឆ** អាចមានទីប្រឹក្សាជាតិ និងអន្តរជាតិមួយចំនួន ដែលមានសមាសភាពជាអ្នកជំនាញ ដើម្បីជួយទ្រទ្រង់លេខាធិការដ្ឋាន ។

**ប្រការ ៦.–**

- **គ.ជ.ស.ឆ** ត្រូវជួបប្រជុំយ៉ាងតិចម្តងក្នុងមួយត្រីមាស តាមការអញ្ជើញរបស់ប្រធាន
- សមាជិកណាដែលមិនអាចមកចូលរួមប្រជុំបាន អាចចាត់តាំងតំណាងអោយចូលរួមប្រជុំជំនួសបាន ។

**ប្រការ ៧.–**

លេខាធិការដ្ឋានរបស់ **គ.ជ.ស.ឆ** ត្រូវបំពេញភារៈកិច្ចតាមការកំណត់របស់ **គ.ជ.ស.ឆ** ។ លេខាធិការដ្ឋានដឹកនាំដោយលេខាធិការមួយរូប និងបុគ្គលិកមានស្រាប់របស់ផ្នែកសំរបសំរួលតំបន់ឆ្នេរសមុទ្រនៃក្រសួងបរិស្ថាន ។

**ប្រការ ៨.–**

គ.ជ.ស.ឆ ត្រូវបង្កើតក្រុមការងារខេត្ត-ក្រុង ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១ - | អភិបាលខេត្ត-ក្រុង | ប្រធាន |
| ២ - | ប្រធានមន្ទីរបរិស្ថាន | អនុប្រធានអចិន្ត្រៃយ៍ |
| ៣ - | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤ - | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៥ - | ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ៦ - | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧ - | ប្រធានមន្ទីរកិច្ចការនារី និងអតីតយុទ្ធជន | សមាជិក |
| ៨ - | ប្រធានមន្ទីរផែនការ | សមាជិក |
| ៩ - | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១០ - | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១១ - | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១២ - | ប្រធានស្នងការនគរបាល | សមាជិក |
| ១៣ - | មេបញ្ជាការកងរាជអាវុធហត្ថ | សមាជិក |
| ១៤ - | មេបញ្ជាការកងនាវាចរប្រចាំខេត្ត-ក្រុង | សមាជិក |

**ប្រការ ៩.-**

ក្រុមការងារខេត្ត-ក្រុង មានតួនាទី និងភារៈកិច្ចដូចខាងក្រោម :

- រៀបចំសកម្មភាពអាទិភាព ដើម្បីគ្រប់គ្រងបរិស្ថានតំបន់ឆ្នេរសមុទ្រ នៅក្នុងខេត្ត-ក្រុង
- សំរបសំរួល គ្រប់ការអនុវត្តនីតំរោងនៅខេត្ត-ក្រុងតំបន់ឆ្នេរ និងមន្ទីរ ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហានៅ តំបន់ឆ្នេរសមុទ្រ
- ផ្តល់យោបល់ជូន **គ.ជ.ស.ឆ** តាមរយៈប្រធានក្រុមការងារខេត្ត-ក្រុង អំពីបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងតំបន់ឆ្នេរសមុទ្រ
- ក្នុងករណីចាំបាច់ អាចបង្កើតក្រុមបច្ចេកទេសធ្វើផែនការ និងអនុវត្តសកម្មភាពផ្សេងៗជាមួយគំរោងតំបន់ឆ្នេរដែលសមាសភាពនៃក្រុមបច្ចេកទេសអាចរួមមាន : បុគ្គលិកដែលមកពីមន្ទីរផ្សេងៗក្នុងខេត្ត ស្រុក ឃុំ និង ភូមិ រួមបញ្ចូលទាំងបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងតំណាងមួយចំនួនមកពីសហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ ដទៃៗទៀត
- ទទួលភារៈកិច្ចផ្សេងៗទៀត ដែល **គ.ជ.ស.ឆ** ប្រគល់អោយ ។

**ប្រការ ១០.-**

ក្រុមការងារខេត្ត-ក្រុង មានសិទ្ធិប្រើប្រាស់ត្រារបស់អាជ្ញាធរខេត្ត-ក្រុង ។

**ប្រការ ១១.-**

មន្ទីរបរិស្ថានខេត្ត-ក្រុង មានតួនាទីជាលេខាធិការដ្ឋាន និងបំពេញភារៈកិច្ចតាមការកំណត់របស់ខេត្ត-ក្រុង ។ លេខាធិការដ្ឋានខេត្ត-ក្រុង ត្រូវដឹកនាំដោយលេខាធិការមួយរូប ។

**ប្រការ ១២.-**

- ក្រុមការងារខេត្ត-ក្រុង ត្រូវជួបប្រជុំរៀងរាល់ខែ តាមការអញ្ជើញរបស់ប្រធាន
- សមាជិកណាដែលមិនអាចមកចូលរួមប្រជុំបាន អាចចាត់តាំងតំណាងអោយចូលរួមប្រជុំជំនួសបាន ។

**ប្រការ ១៣.-**

- អង្គការមិនមែនរដ្ឋាភិបាលនិងអ្នកផ្តល់ជំនួយ ដែលមានគំរោងកម្មវិធីពាក់ព័ន្ធទៅនឹងតំបន់ឆ្នេរសមុទ្រ អាចចូលរួមប្រជុំក្នុង **គ.ជ.ស.ឆ** និងក្រុមការងារខេត្ត-ក្រុង ក្នុងនាមជាអ្នកសង្កេតការណ៍ ។

- លេខាធិការដ្ឋានរបស់ **គ.ជ.ស.ឆ** និងក្រុមការងារខេត្ត-ក្រុងនីមួយៗ ត្រូវជូនដំណឹងដល់អ្នកសង្កេតការណ៍ អំពីពេលវេលា និងទីកន្លែងប្រជុំរបស់សមាជិក **គ.ជ.ស.ឆ** ឬក្រុមការងារ ខេត្ត-ក្រុង ។
- អ្នកសង្កេតការណ៍មានសិទ្ធិចូលរួមប្រជុំ ប៉ុន្តែមិនអាចចូលរួមជាសមាជិកបានឡើយ ។
- ប្រធាន **គ.ជ.ស.ឆ** ឬក្រុមការងារខេត្ត-ក្រុង ដោយគំនិតផ្តួចផ្តើមខ្លួនផ្ទាល់ ឬក៏តាមសំណូមពររបស់សមាជិកអាចសុំជាគំនិតយោបល់ និងទស្សនៈរបស់អ្នកសង្កេតការណ៍ ទៅលើប្រធានបទដែលកំពុងពិភាក្សានៅក្នុងពេលប្រជុំ ។

**ប្រការ ១៤.-**

- ប្រធាន **គ.ជ.ស.ឆ** និងប្រធានក្រុមការងារខេត្ត-ក្រុង ត្រូវតាក់តែងរបៀបវារៈសំរាប់កិច្ចប្រជុំ និងដឹកនាំកិច្ចប្រជុំ ។

**ប្រការ ១៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នខេត្ត-ក្រុងដែលពាក់ព័ន្ធនឹងសេចក្តីសំរេចនេះ ត្រូវអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១៥
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦៤ សសរ

# សេចក្ដីសំរេច

## ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងស្រាវជ្រាវ
## បាតុភាពមិនប្រក្រតីនាំមនុស្សទៅបរទេសនៅក្រសួងទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១.-**

បង្កើតគណៈកម្មការអន្តរក្រសួងស្រាវជ្រាវបាតុភាពមិនប្រក្រតីនាំមនុស្សទៅសហរដ្ឋអាមេរិក នៅក្រសួងទេសចរណ៍ ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម ស៊ាន វិសុទ្ធ | សមាជិកអចិន្ត្រៃយ៍នៃអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ | ប្រធាន |
| ២- ឯកឧត្តម យូ ស៊ិនឡុង | ទីប្រឹក្សាសម្ដេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្តម រស់ សូផាន់ | អគ្គនាយក នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៤- ឯកឧត្តម អ៊ុំ ហុកលីម | អគ្គាធិការ នៃក្រសួងកសិកម្ម | សមាជិក |
| ៥- ឧត្តមសេនីយត្រី យ៉ុន ឈុន្នី | ប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ | សមាជិក |
| ៦- លោក សៅ សារឿន | អធិការ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៧- លោក ឆាយ សុខន | ប្រធាននាយកដ្ឋានច្បាប់ និង កុងស៊ុលក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |

ប្រការ ២.—

គណៈកម្មការនេះមានភារកិច្ច :

- ធ្វើការស្រាវជ្រាវបាតុភាពមិនប្រក្រតី ក្នុងគណៈប្រតិភូទៅសហរដ្ឋអាមេរិក ដោយប្រើប្រាស់លិខិតឆ្លងដែនផ្លូវការ និងយកឈ្មោះក្របខ័ណ្ឌមន្ត្រីក្រសួងទេសចរណ៍ នៃគណៈប្រតិភូដែលដឹកនាំដោយឯកឧត្តម ជ័យ សម្បូរណ៍ អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍
- ធ្វើការទំនាក់ទំនង និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលផ្តុំលិខិតឯកសារ និងពត៌មាននានាជុំវិញករណីខាងលើ
- បូកសរុបលទ្ធផលនិងវាយតម្លៃអោយបានច្បាស់លាស់រួចរាយការណ៍ជូនរាជរដ្ឋាភិបាលដើម្បីមានវិធានការណ៍ជាក់ស្តែង ។

ប្រការ ៣.—

សមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសំរួលការងារ ។

ប្រការ ៤.—

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៥.—

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
គណៈបញ្ជាការការពារការបោះឆ្នោត
ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
លេខ : ..១១...គ.ព.ក.ឃ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០១

# សេចក្តីណែនាំ

ក្នុងវត្ថុបំណង ពង្រឹងស្ថេរភាព និង សន្តិសុខនយោបាយ លើកកំពស់ការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស បង្កើតបរិយាកាសនយោបាយអព្យាក្រឹត្យ និង គោរពសិទ្ធិសេរីភាពក្នុងរាល់សកម្មភាពនយោបាយរបស់ឥស្សរជន នយោបាយ និង គណបក្សនយោបាយស្របច្បាប់ទាំងអស់ ការិយាល័យសន្តិសុខថ្នាក់កណ្តាលនៃគណៈបញ្ជាការ ការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ សូមធ្វើការណែនាំដល់អាជ្ញាធរដែនដី កងកំលាំងមានសមត្ថកិច្ច និងការិយាល័យសន្តិសុខគ្រប់ថ្នាក់ អោយបំពេញភារកិច្ច និងកាតព្វកិច្ចរបស់ខ្លួនដូចតទៅ :

១-ត្រូវក្តាប់អោយបានច្បាស់រាល់ខ្លឹមសារដែលបានកំណត់ក្នុងច្បាប់ ក្នុងកម្មវិធីនយោបាយ និង គោលការណ៍ ផ្សេងៗរបស់រាជរដ្ឋាភិបាល ក្នុងសេចក្តីណែនាំផ្សេងៗរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត របស់ក្រសួងមហាផ្ទៃ និងរបស់ក្រសួងការពារជាតិ ។ ត្រូវពង្រឹង និង អនុវត្តតួនាទីរបស់ខ្លួនដែលបានកំណត់ ជាពិសេសត្រូវយកចិត្តទុកដាក់ រក្សាអព្យាក្រឹត្យភាពរបស់ខ្លួន បន្តអនុវត្តដោយស្មារតីទទួលខុសត្រូវនូវកាតព្វកិច្ច សីលធម៌ អាកប្បកិរិយា វិន័យ របស់កងកំលាំង ។

២-ត្រូវខិតខំពង្រឹងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងសង្គម ដោយសហការគ្នាអោយបានស្អិតល្មួតក្នុងការបង្ការ បង្ក្រាបរាល់បទល្មើសផ្សេងៗ ទប់ស្កាត់ការបង្កចលាចលនានា អំពើហិង្សា អំពើបំភិតបំភ័យ អំពើគំរាមកំហែង និង អំពើ រារាំងប្រជាពលរដ្ឋមិនអោយចូលរួមក្នុងដំណើរការបោះឆ្នោត ដោយត្រូវធានាអនុវត្តអោយបានត្រឹមត្រូវតាមការកំណត់ របស់ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

៣-ត្រូវចាត់វិធានការ ការពារអោយបានហ្មត់ចត់គ្រប់ទីស្នាក់ការគណៈបក្សនយោបាយទាំងឡាយ ដែលមាន ច្បាប់អនុញ្ញាត និង បានចុះបញ្ជីត្រឹមត្រូវទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ។ គណបក្សនយោបាយដែលមានច្បាប់អនុញ្ញាត ត្រឹមត្រូវ មានសិទ្ធិលើផ្លាកសញ្ញាគណបក្សរបស់ខ្លួនទៅតាមមូលដ្ឋាន ប៉ុន្តែត្រូវជូនព័ត៌មានទៅអាជ្ញាធរដែនដីអោយបាន ជ្រាបជាមុនសិន ។

៤-ត្រូវចាត់វិធានការ ការពារសន្តិសុខសុវត្ថិភាព និង គោរពសិទ្ធិសេរីភាពរបស់អ្នកនយោបាយដែលធ្វើសកម្មភាពនយោបាយត្រឹមត្រូវតាមច្បាប់ ។ អ្នកនយោបាយណាដែលមានបំណងជួបប្រាស្រ័យជាមួយប្រជាពលរដ្ឋ ក្នុងលក្ខណៈ ប្រមូលផ្តុំត្រូវផ្តល់ដំណឹងជាលាយលក្ខអក្សរ អំពីទីកន្លែង ពេលវេលា ជូនអាជ្ញាធរដែនដីមូលដ្ឋានជាមុន ដើម្បីងាយស្រួលក្នុងការចាត់វិធានការការពារសន្តិសុខ ។ ក្នុងករណីដែលអ្នកនយោបាយនោះមិនបានជូនដំណឹង ឬ ផ្តល់ពត៌មានជាមុនទេនោះ ប្រសិនបើមានហេតុការណ៍ ឬ ឧប្បទ្ទវហេតុ ផ្សេងៗ កើតឡើង អ្នកនយោបាយនោះ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

៥-ត្រូវសហការអោយបានស្និតល្អតល្អជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅតាមបណ្តាថ្នាក់ ដើម្បីដោះស្រាយដោយសន្តិវិធីរាល់បញ្ហាដែលកើតឡើង ជៀសវាងការធ្វើអោយមានចលាចល បាត់សណ្តាប់ធ្នាប់ បំភិតបំភ័យ គំរាមគំហែង ។ ឧប្បទ្ទវហេតុដែលកើតឡើង ត្រូវរួសរាន់ធ្វើការស្រាវជ្រាវស៊ើបអង្កេត ប្រមែប្រមូលភស្តុតាង ដើម្បីលាតត្រដាង អំពីចរិតពិតប្រាកដនៃរឿងហេតុទាំងនោះ រួចហើយកសាងសំណុំរឿងបញ្ជូនទៅតុលាការវិនិច្ឆ័យតាមច្បាប់ ។

ទទួលបានសេចក្តីណែនាំនេះ អាជ្ញាធរដែនដី កងកំលាំងមានសមត្ថកិច្ច និងការិយាល័យសន្តិសុខថ្នាក់ខេត្ត ក្រុង ថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ត្រូវលើកកំពស់ស្មារតីទទួលខុសត្រូវ និងត្រូវទទួលអនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។

**៤.គណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើស**

**ក្រុមប្រឹក្សាឃុំ សង្កាត់**

**ប្រធាន**

**ស ខេង**

***ចំលងជូនៈ***

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

"ដើម្បីជូនជ្រាប" ។

-ក្រសួងមហាផ្ទៃ

-ក្រសួងការពារជាតិ

-អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ

-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស

-ការិយាល័យសន្តិសុខថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ឃុំ សង្កាត់

-ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០១-១៦៦ ប្រក.

# ប្រកាស

## ស្តីពី

## ប្រាក់តំកល់ធានាលើដើមទុន

### ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១១៩៩ / ១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ០៣៩៨ / ៨៥ ចុះថ្ងៃទី ១០ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

### ស ម្រេ ច

**ប្រការ ១.-**

កំណត់ប្រាក់តំកល់ធានាលើដើមទុនដែលត្រូវដាក់ផ្ញើជាអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា ដូចមានចែងក្នុងមាត្រា១៦នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ចំនួន១០ភាគរយនៃដើមទុន ។

**ប្រការ ២.-**

ប្រាក់តំកល់ធានាលើដើមទុនដែលមានស្រាប់ គិតមកដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០០ នឹងត្រូវបំពេញអោយដល់ចំនួនយ៉ាងតិចដប់ភាគរយ ( ១០ % ) នៃដើមទុនចុះបញ្ជីរបស់ធនាគារអោយបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១ ។

ប្រការ ៣.-

ធនាគារដែលត្រូវបានអនុញ្ញាតអោយពន្យារពេលសំរាប់បង្កើនដើមទុនអប្បបរមាដល់កំរិតចំនួន - ហាសិបពាន់លានរៀល ( ៥០.០០០.០០០.០០០រ ) ក្នុងឆ្នាំ២០០១ នឹងត្រូវបង់ប្រាក់តំកល់ធានាលើដើមទុន តាមសមាមាត្រនៃដើមទុនដែលបានបង់តាមដំណាក់កាលដែលភាគទុនិកបានសន្យា ។

ក្នុងករណី ការបង្កើនដើមទុនត្រូវបានដកយកមកពីប្រាក់ចំណេញរក្សាទុក ( Retained Earning ) ប្រាក់តំកល់ធានាលើដើមទុន ត្រូវបានបង់ព្រមពេលជាមួយនឹងការសំរេចរបស់ភាគទុនិកអោយផ្ទេរប្រាក់ចំណេញមកជាដើមទុន ។

ប្រការ ៤.-

ប្រាក់តំកល់ធានាលើដើមទុនអាចអនុវត្តជាប្រាក់រៀល ឬជាប្រាក់ដុល្លារអាមេរិក ។ បន្ទាប់ពីបានបង់ប្រាក់តំកល់ធានាលើដើមទុន ធនាគារសាមីមិនអាចផ្លាស់ប្តូរការជ្រើសរើសនេះបានទេ ។ អត្រាប្តូរប្រាក់ប្រើប្រាស់សំរាប់ការគណនាប្រាក់តំកល់ធានាលើដើមទុននេះ គឺជាអត្រាប្តូរប្រាក់ផ្លូវការនៅថ្ងៃដែលមូលនិធិត្រូវបានចុះឥណទានគណនីតំកល់ធានានៅធនាគារជាតិនៃកម្ពុជា ។

ប្រការ ៥.-

ប្រាក់តំកល់ធានាលើដើមទុនជាប្រាក់រៀលទទួលបានកំរៃការប្រាក់ មួយភាគពីរនៃអត្រាការប្រាក់បុនហិរញ្ញប្បទានក្នុងរយៈពេល ៦ ខែម្តងជាធរមាន ដែលកំណត់ដោយធនាគារជាតិនៃកម្ពុជា ។

ប្រាក់តំកល់ធានាលើដើមទុនជារូបិយប័ណ្ណបរទេស ទទួលបានកំរៃការប្រាក់តាមអត្រា ៣/ ៨ នៃ SIBOR ( Singapore Inter-Bank Offered Rate ) ក្នុងរយៈពេល៦ខែម្តង ។ ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងទៅធនាគារទាំងអស់ពីអត្រាការប្រាក់ដែលបានអនុវត្តសំរាប់កាលកំណត់ និមួយៗ ។

ប្រការ ៦.-

ប្រាក់តំកល់ធានាលើដើមទុន ត្រូវបានសងត្រលប់ទៅវិញតែក្នុងករណីមានការជំរះបញ្ជីធនាគារ និងស្របតាមលំដាប់អាទិភាពដែលមានចែងនៅមាត្រា៦៤ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៧.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀង១ខ្លួន ។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 15 ខែ 10 ឆ្នាំ២០០១

ទេសាភិបាល

ជា ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ៨ " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីជ្រាបជាពត៌មាន "
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី " ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១-១៣៤ ប្រក

# ប្រកាស

## ស្តីពី

## ឥណទានចំពោះសម្ព័ន្ធញាតិ

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០១៩៦/ ២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ១១៩៩/ ១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៣៩៨/ ៨៥ ចុះថ្ងៃទី ១០ មិនា ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

## សំរេច

**ប្រការ ១.-**

សម្ព័ន្ធញាតិដូចមានចែងនៅមាត្រាទី ៤៩ និង ៥០ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមបញ្ញត្តិនៃប្រកាសនេះ ។

**ប្រការ ២.-**

ឥណទាន និងឥណទានលើសសមតុល្យចំពោះសម្ព័ន្ធញាតិ ត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌធម្មតានៃថេរៈវេលាអត្រាការប្រាក់ វត្ថុបញ្ចាំ និងកាលវិភាគត្រូវទូទាត់សងវិញ ។

ល័ក្ខខ័ណ្ឌធម្មតាក្នុងន័យនេះ គឺជាល័ក្ខខ័ណ្ឌដែលត្រូវអនុវត្តចំពោះអតិថិជនមិនមែនសម្ព័ន្ធញាតិក្នុងកាលៈទេសៈដូចគ្នា ។

**ប្រការ ៣.-**

បញ្ញត្តិដែលមានចែងក្នុងមាត្រា ២ មិនអនុវត្តចំពោះបំណុលបំពេញលើដើមទុន ( Subordinated debts ) ដែលផ្តល់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា និងកាន់កាប់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុកម្ពុជាដែលជាក្រុមហ៊ុនមេរបស់ពួកគេឡើយ ។

**ប្រការ ៤.-**

សរុបសមតុល្យឥណទានចំពោះសម្ព័ន្ធញាតិមិនអាចខ្ពស់ជាង ១០% នៃមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារទេ ។

សមតុល្យឥណទានត្រូវគណនាស្របតាមប្រកាស ស្តីពីអនុបាតសាធនភាព ( លេខ ធ៧.០០-៤៦ប្រក ) ។

មូលនិធិផ្ទាល់សុទ្ធរបស់ធនាគារត្រូវគណនាស្របតាមប្រកាស ស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ធនាគារ ( លេខ ធ ៧.០០ - ៤៧ ប្រក) ។

**ប្រការ ៥.-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនីមួយៗ ត្រូវធ្វើប្រតិវេទន៍ប្រចាំត្រីមាសលើឥណទានដែលពាក់ព័ន្ធជូនធនាគារជាតិនៃកម្ពុជា ស្របតាមគំរូដែលមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

អត្ថបទចំលងនៃប្រតិវេទន៍នេះ ត្រូវចំលងជូនក្រុមប្រឹក្សាភិបាលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៦.-**

ការខកខានមិនបានអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ត្រូវទទួលរងទណ្ឌកម្មដែលមានចែងត្រង់មាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។

**ប្រការ ៧.-**

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ នៅក្រោមឪវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ច រៀង១ខ្លួន ។

**ប្រការ ៩.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 15 ខែ 10 ឆ្នាំ ២០០១

ទេសាភិបាល

ជា . ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- គ្រប់សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

# សារាចរណែនាំស្តីពីឥណទានចំពោះសម្ព័ន្ធញាតិ
# CURCULAR ON LOANS TO RELATED PARTIES

យោងប្រកាសលេខ ............................................ ស្តីពីឥណទានចំពោះសម្ព័ន្ធញាតិ
With reference to Prakas N° ................................ on loan to related parties

ប្រតិវេទន៍ប្រចាំត្រីមាសយោងប្រការ ៥ នៃប្រកាសនេះ ត្រូវមានគំរូដូចតទៅ ÷
The quarterly declaration referred to in Art 5 of the above mentioned Prakas shall have the following format

| ឈ្មោះនិងអាស័យដ្ឋានអ្នកខ្ចី Name and address of borrower | ប្រភេទឥណទាន Type of loan | កាលបរិច្ឆេទឥណទាន Date of loan | ចំនួនទឹកប្រាក់ឥណទានដើម Initial amount | សរុបទឹកប្រាក់ឥណទាន Outstanding amount | អត្រាការប្រាក់ Rate of Interest | វត្ថុបញ្ចាំ Collateral | ទំងន់ហានិភ័យឥណទានយោងតាមប្រកាសលេខ ធ៧-០០-៤៦ Weighting according to Prakas B 7-00-46 | សរុបទំងន់ហានិភ័យឥណទាន Weighted oustanding |
|---|---|---|---|---|---|---|---|---|
| | | | | | | | | |
| សរុប Total Outstanding | | | | | | | | |

| | |
|---|---|
| សរុបមូលនិធិផ្ទាល់សុទ្ធដូចបានគណនាតាមប្រកាសលេខ ធ៧-០០-៤៧ Total Net worth as calculated in Prakas B7-00-47 | |

| | |
|---|---|
| ភាគរយនៃឥណទានសម្ព័ន្ធញាតិធៀបទៅនឹងមូលនិធិផ្ទាល់សុទ្ធ Percentage of loan to related parties into net worth | |

| អ្នករៀបចំ | អ្នកពិនិត្យ | ហត្ថលេខានាយកធនាគារ |
|---|---|---|
| **Preparer** | **Controller** | **Signature of Bank Manager** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និង ដឹកជញ្ជូន**
លេខ 377 ក្រសក.

ភ្នំពេញ, ថ្ងៃទី 11 ខែ 10 ឆ្នាំ ២០០១

# ប្រកាស

## ស្តីពីការកំណត់អោយប្រើប្រាស់ជាផ្លូវការ នូវ បទដ្ឋានបច្ចេកទេស ស្ពាន-ថ្នល់

## រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃ ព្រះរាជាណាចក្រកម្ពុជា លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០.១១.១៩៩៨ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញ ព្រះរាជក្រមលេខ នស/ រកម/ ០១៩៦.០៣ ចុះថ្ងៃទី ២៤.០១.១៩៩៦ ស្តីពីការបង្កើត ក្រសួង សាធារណការ និង ដឹកជញ្ជូន ។
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន ។
- បានឃើញ អនុក្រឹត្យលេខ ១៨/អនក្រ.បក ចុះថ្ងៃទី ០៣.០៣.១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ ក្រសួងសាធារណការ និង ដឹកជញ្ជូន ។
- យោង តាមការចាំបាច់របស់ក្រសួង ។

## សំរេច

ប្រការ ១ : រាល់ការងារសិក្សាគំរោង ឬការងារសំណង់ ទាក់ទងទៅនឹងរចនាសម្ព័ន្ធ ស្ពាន-ថ្នល់ ក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់អនុលោមតាមឯកសារបទដ្ឋានបច្ចេកទេសស្ពាន-ថ្នល់ ដែលមានចែងដូច ខាងក្រោម :

១. **ការងារសិក្សាគំរោងស្ពាន :**

១.១- CAM PW 04-101-99 : បទដ្ឋានសិក្សាគំរោង ស្ពាន នៃប្រទេស អូស្ត្រាលី ឆ្នាំ ១៩៩៦ និង កំរងខ្លឹមសារពន្យល់ (បទដ្ឋានគ្រឹះ), Australian Bridge Design Code 1996 and Associated Commentary.

១.២- CAM PW 04-102-99 : បទដ្ឋានសិក្សាគំរោងស្ពាន និង កំរងខ្លឹមសារ ពន្យល់ (កំរងខ្លឹមសារបច្ចេកទេស ស្ពាន ដែលត្រូវបានកែប្រែ ឬបន្ថែមទៅលើខ្លឹមសារបច្ចេកទេស មួយចំនួននៃបទដ្ឋានគ្រឹះ CAM PW 04-101-99 ដើម្បីអោយស្របទៅនឹង តំរូវការជាក់ស្តែងនៃព្រះរាជាណាចក្រកម្ពុជា) Bridge Design Standard and Commentary។

២. **ការងារសិក្សាគំរោងថ្នល់ :**

២.១- CAM PW 03-101-99 បទដ្ឋានសិក្សាគំរោងថ្នល់ ផ្នែកទី ១ ធរណីមាត្រ, Road Design Standard, Part 1 – Geometry

២.២- CAM PW 03-102-99 បទដ្ឋានសិក្សាគំរោងថ្នល់ ផ្នែកទី ២ កំរាលថ្នល់ Road Design Standard, Part 2 – Pavement

២.៣- CAM PW 03-103-99 បទដ្ឋានសិក្សាគំរោងថ្នល់ ផ្នែកទី ៣ ប្រព័ន្ធបង្ហូរទឹក Road Design Standard, Part 3 – Drainage

៣. **បទដ្ឋានបច្ចេកទេស ក្នុងការងារអនុវត្តន៍សំណង់ ស្ពាន-ថ្នល់** (Construction Specifications) :

៣.១- ផ្នែកទី ១, លក្ខណៈបច្ចេកទេសទូទៅ (General Specification)

៣.២- ផ្នែកទី ២, ការងារ និង សកម្មភាពទាក់ទង នឹង ការងារ ជីក ឈូសឆាយដី (Earthworks and Allied Activities)

៣.៣- ផ្នែកទី ៣, ប្រព័ន្ធគ្រឹះថ្នល់ (Subbase and Basecourse)

៣.៤- ផ្នែកទី ៤, ការងារប៊ីទូម (Bituminous Works)

៣.៥- ផ្នែកទី ៥, រចនាសម្ព័ន្ធ (Structures)

៣.៦- ផ្នែកទី ៦, ប្រព័ន្ធបង្ហូរទឹក និង ប្រព័ន្ធ ការពារ ការហូរច្រោះ (Drainage and Protection Works)

៣.៧- ផ្នែកទី ៧, ការងារជំនួយបន្ថែម (Ancillary Works)

៣.៨- ផ្នែកទី ៨, គ្រឿងផ្ទុះដែលបង្កប់ក្នុងដី (Unexploded Ordnance)

៣.៩- ផ្នែកទី ៩, ការងារផ្សេងៗ (Miscellaneous)

៣.១០- ផ្នែកទី ១០, ការងារកត់ត្រាប្រចាំថ្ងៃ (Day work)

ប្រការ ២ : រាល់ការកែប្រែ ឬ បន្ថែមទៅលើខ្លឹមសារបច្ចេកទេសទាំងឡាយដែលមានចែងក្នុងបទដ្ឋានខាងលើអាចមានប្រសិទ្ធិភាពទៅបានលុះត្រាតែមានការប្រកាសផ្សព្វផ្សាយ ជាផ្លូវការ ដោយក្រសួងសាធារណការ និង ដឹកជញ្ជូន ។

ប្រការ ៣ : នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយករដ្ឋបាល-អគ្គនាយកនៃអគ្គនាយកសាធារណការ និងអង្គភាព នានា ដែលពាក់ព័ន្ធទៅនឹង ការងារស្ពាន-ថ្នល់ មានភារៈកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

**រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន**

ឃិ តាំងលឹម

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងធនធានទឹក និងឧតុនិយម
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងផែនការ
- វិទ្យាស្ថាន បច្ចេកវិទ្យា កម្ពុជា

**" ដើម្បីជូនជ្រាប "**

- ដូចប្រការ ៣ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

# Cambodian Road and Bridge Design Standard and Construction Specifications

The Standard consists of the following documents:

## 1. Bridge Design Standard

| | | |
|---|---|---|
| 1.1 | CAM PW 04-101-99 | Australian Bridge Design Code 1996 (the Base Document) and associated Commentary; |
| 1.2 | CAM PW 04-102-99 | - This Document (the Amendments), which contains amendments and additions to the Base Document; and |
| | | - The Commentary on the Cambodian Bridge Design Standard, which contains amendments and additions to the Commentary on the Base Document. |

## 2. Road Design Standard

| | | |
|---|---|---|
| 2.1 | CAM PW 03-101-99 | Road Design Standard – Part 1 – Geometry |
| 2.2 | CAM PW 03-102-99 | Road Design Standard – Part 2 – Pavement |
| 2.3 | CAM PW 03-103-99 | Road Design Standard – Part 3 – Drainage |

## 3. Construction Specifications

| | | |
|---|---|---|
| 3.1 | Section 1 | General Specification |
| 3.2 | Section 2 | Earthworks and Allied Activities |
| 3.3 | Section 3 | Sub-base and Base-course |
| 3.4 | Section 4 | Bituminous Works |
| 3.5 | Section 5 | Structures |
| 3.6 | Section 6 | Drainage and Protection Works |
| 3.7 | Section 7 | Ancillary Works |
| 3.8 | Section 8 | Unexploded Ordnance |
| 3.9 | Section 9 | Miscellaneous |
| 3.10 | Section 10 | Daywork |

Kingdom of Cambodia
Ministry of Public Works and Transport
Public Works Research Centre

**Cambodian Bridge Design Standard (1 section + 1 set)**
- **CAM PW 04-101-99**
- **CAM PW 04-102-99**




**Cambodian Road Design Standard (3 sections)**
- **CAM PW 03-101-99**
- **CAM PW 03-102-99**
- **CAM PW 03-103-99**




**Construction Specifications for Bridge and Road (10 sections)**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ : ៧២៥. សកបយ.

ភ្នំពេញ. ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## ការឈប់សំរាកពិសេស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋា-ភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ មានសិទ្ធិអនុញ្ញាតអោយកម្មករនិយោជិតខ្លួនបានឈប់សំរាកពិសេសដោយមានប្រាក់ឈ្នួល ដែលមានថិរវេលាមិនលើសពីប្រាំពីរថ្ងៃក្នុងមួយឆ្នាំ ក្នុងឱកាសដែលកម្មករនិយោជិតមានធុរៈផ្ទាល់ខ្លួន ឬក្នុងឱកាសមានព្រឹត្តិការណ៍ប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃកម្មករនិយោជិតនោះ ដូចជា :-

-ការរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន

-ប្រពន្ធសំរាលកូន

-រៀបអាពាហ៍ពិពាហ៍កូន

-ប្តី ប្រពន្ធ កូន ឪពុក ម្តាយមានជម្ងឺ ឬទទួលមរណភាព ។

**ប្រការ២.-** និយោជកអាចធ្វើការកាត់កងការឈប់សំរាកពិសេសនេះ ពីការឈប់សំរាកប្រចាំឆ្នាំរបស់កម្មករនិយោជិត បើកម្មករនិយោជិតនោះមិនទាន់អនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនទេ ឬអាចតំរូវអោយកម្មករនិយោជិតធ្វើការសងវិញ បើកម្មករនិយោជិតនោះបានអនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនហើយ ។

**ប្រការ៣.-** ការធ្វើការសងអាចអនុវត្តបានតែក្នុងរយៈពេល ៩០ ថ្ងៃក្រោយថ្ងៃឈប់សំរាកពិសេស ។ ការធ្វើការសងត្រូវអនុវត្តក្នុងថ្ងៃធ្វើការធម្មតា និងក្នុងល័ក្ខខ័ណ្ឌដែលថិរវេលាធ្វើការសរុបមិនលើសពី ១០ ម៉ោង ក្នុងមួយថ្ងៃ ឬលើសពី ៥៤ ម៉ោង ក្នុងមួយសប្តាហ៍ ។

**ប្រការ៤.-** ការធ្វើការសងត្រូវអោយឈ្នួលតាមអត្រាពេលម៉ោងធ្វើការធម្មតា ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៧៦ សករអ.ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អ៊ិត សំហេង

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ

-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក

-សហព័ន្ធសហជីព

"ដើម្បីអនុវត្ត"

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"

-រាជកិច្ច

-កាលប្បវត្តិ និងឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សក MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ [illegible] សកបយ.

ភ្នំពេញ. ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## ស ម្រេ ច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវប្រើ និងរក្សាទុកអោយបានត្រឹមត្រូវនូវសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមួយ ដែលអធិការការងារបានចុះលេខរៀង និងចុះហត្ថលេខាសង្ខេប ។ គំរូសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២.-** និយោជក ឬអ្នកតំណាងត្រូវជូនសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាននេះ ទៅអធិការការងារ ឬអភិបាលការងារ ត្រួតពិនិត្យនិងធ្វើការសង្កេត ធ្វើការផ្តល់ដំបូន្មាន ឬធ្វើការដាក់កំហិតផ្សេងៗ នៅរាល់ពេលចុះត្រួតពិនិត្យ ។

**ប្រការ៣.-** សៀវភៅបញ្ជីប្រចាំគ្រឹះស្ថានដែលបានប្រើប្រាស់គ្រប់ទំព័រទាំងអស់ហើយ និយោជកត្រូវថែរក្សាទុកអោយគង់ក្នុងរយៈពេល ៣ ឆ្នាំ ។ អធិការការងារ និងអភិបាលការងារអាចទាររកសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាននោះ នៅគ្រប់ពេលវេលា ។

**ប្រការ៤.-** អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលការពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងនៅក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៩២ សកអ.ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

អ៊ិត សំហេង

ឧបសម្ព័ន្ធ

នៃ

ប្រកាសលេខ :.....................

ចុះថ្ងៃទី........ខែ.........ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

..................ថ្ងៃទី........ខែ...........ឆ្នាំ...........

ទំហំ ២០សម X ៣០សម

-ឈ្មោះគ្រឹះស្ថាន :..........................................................................

..........................................................................

-ផ្នែកនៃសកម្មភាពសេដ្ឋកិច្ច :..........................................................................

..........................................................................

-អាសយដ្ឋាន :..........................................................................

..........................................................................

-នាមនិងគោត្តនាមនិយោជក :..........................................................................

..........................................................................

-កាលបរិច្ឆេទនៃការចេញសៀវភៅបញ្ជី :..........................................................................

..........................................................................

**បោះព្រាហ្មលេខា**

**របស់អធិការការដ្ឋាន**

**លេខទំព័រ:................**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខ : ៧៦៨ សកបយ.

ភ្នំពេញ, ថ្ងៃទី ១១ ខែ ៩ ឆ្នាំ២០០១

# ប្រកាស

## ស្តីពី

## ការបង្កើតសៀវភៅបើកប្រាក់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវកាន់ដោយទៀងទាត់ជាដរាប នូវសៀវភៅបើកប្រាក់មួយដូចគំរូក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២.-** សៀវភៅបើកប្រាក់នេះនឹងទុកជាត្រឹមត្រូវបាន លុះត្រាមានចុះលេខទំព័រ និងចុះហត្ថលេខាសង្ខេបគ្រប់ទំព័រដោយអធិការការងារ ។

និយោជក នៃសហគ្រាស គ្រឹះស្ថានណាចង់ធ្វើសៀវភៅបើកប្រាក់តាមរបៀបផ្សេងពីគំរូដូចមានចែង

ក្នុងប្រការ១ ខាងលើ ប៉ុន្តែមានចុះពតិមាន និងបែបបទត្រួតពិនិត្យដូចគ្នានោះ ត្រូវធ្វើពាក្យសុំទៅនាយកដ្ឋានអធិការកិច្ចការងារ (ចំពោះសហគ្រាស គ្រឹះស្ថាននៅរាជធានីភ្នំពេញ) និងនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត -ក្រុងបាន (ចំពោះសហគ្រាស គ្រឹះស្ថាននៅខេត្ត- ក្រុងផ្សេងទៀត)។

**ប្រការ៣.**~ សៀវភៅបើកប្រាក់នេះត្រូវទុកនៅក្នុងការិយាល័យបេឡា ឬទីចាត់ការនៃសហគ្រាស គ្រឹះស្ថាន ដើម្បីងាយស្រួលដល់ការត្រួតពិនិត្យ ។ កាលណាប្រើសៀវភៅនេះគ្រប់ទំព័រហើយ និយោជកត្រូវមានកាតព្វកិច្ចរក្សាទុកអោយគង់វង់ក្នុងរយៈពេល ៣ឆ្នាំ។

អធិការការងារ ឬអភិបាលការងារអាចទាររកសៀវភៅនេះ នៅគ្រប់ពេលវេលា។

**ប្រការ៤.**~ អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃប្រកាសនេះត្រូវទទួលការពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ។

**ប្រការ៥.**~ ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ៩៣ សកអ. ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៦.**~ ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ✓

**រដ្ឋមន្ត្រី**

**ឌិត សំហេង**

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា ខេត្ត-ក្រុង
"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក
-សហព័ន្ធសហជីព
"ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធ
នៃប្រកាសលេខ........
ចុះថ្ងៃទី.......ខែ..........ឆ្នាំ

# សៀវភៅបើកប្រាក់
LE LIVRE DE PAYE

**គ្រឹះស្ថាន.....................**
ETABLISSEMENT

**ផ្នែកនៃសកម្មភាពសេដ្ឋកិច្ច.........................**
BRANCHE D'ACTIVITE ECONOMIQUE

**អាសយដ្ឋាន.............................**
ADDRESSE

( ទំហំ ២៥ ស.ម គុណ ៣៥ ស.ម )

# សៀវភៅបើកប្រាក់

# LE LIVRE DE PAYE

គ្រឹះស្ថាន ______________________

ETABLISSEMENT ______________________

ផ្នែកសកម្មភាពសេដ្ឋកិច្ច ______________________

BRANCHE D'ACTIVITE ECONOMIQUE ______________________

អាសយដ្ឋាន ______________________

ADRESSE ______________________

ប្រចាំខែ......................

| លរ<br>No | ឈ្មោះត្រកូលនិងនាមខ្លួន<br>នៃកម្មករ និយោជិត<br>Nom et prénom<br>du salarié | សញ្ជាតិ<br>Natio-<br>nalité | មុខការងារកាន់កាប់<br>ក្នុងសហគ្រាស<br>Fonction<br>occupée<br>dans<br>l'entreprise | ស្ថានភាព<br>គ្រួសារ<br>Situation<br>de famille<br>ប្រពន្ធ<br>Fem-<br>me | <br><br><br><br>កូន<br>En-<br>fant | ប្រាក់ថ្ងៃ ឬ<br>ប្រាក់ខែ<br>Salaire<br>journalier<br>ou<br>mensuel | វិភាគទាន<br>គ្រួសារ<br>Alloca-<br>tions<br>famili-<br>ales | ប្រាក់ម៉ោងធ្វើ<br>ការបន្ថែម<br>Indemnité<br>pour<br>heures<br>supplé-<br>mentaires | ប្រាក់ជូនការ<br>ឱ្យដំណឹងមុន<br>ឬប្រាក់ខូចខាត<br>ការលេង<br>Preavis ou<br>delai congé | ប្រាក់ឈប់<br>សំរាក<br>ប្រចាំឆ្នាំ<br>Congé<br>annuel<br>payé | ប្រាក់បំណាច់<br>ផ្សេងៗ<br>Autres<br>indem-<br>nité ou<br>primes |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |
| | | | | | | | | | | | |

..........ឆ្នាំ.................. ទំព័រ......................

| ចំនួនទឹកប្រាក់ទាំងអស់ដែលត្រូវបើក Total des sommes à payer | ប្រាក់ហូតទុក Retenues | | | | | ចំនួនប្រាក់ដែលកាត់ទាំងអស់ Total des retenues | ចំនួនប្រាក់ដែលត្រូវបើក Montant net à payer | ហត្ថលេខា Emargement | សេចក្តីផ្សេងៗ Observations |
|---|---|---|---|---|---|---|---|---|---|
| | ចំនួនប្រាក់ខ្ចី Montant des avances accordées | កាត់ប្រាក់ខ្ចី Déduction des avances | ប្រាក់បន្ថយថ្ងៃឈប់ Déduction des journées de congé | ពន្ធ និងវិភាគទាន Taxe et contribution | | | | | |
| | | | | សន្តិសុខសង្គម Sécurité sociale | ពន្ធលើប្រាក់បៀវត្ស ITS | | | | |
| 13(7+8+9+10+11+12) | 14 | 15 | 16 | 17 | 18. | 19(15+16+17+18) | 20(13-19) | 21 | 22 |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងផែនការ**

លេខៈ...[illegible]......ផក.ទទអជ

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋានសំរាប់គណៈកម្មាធិការជាតិ រៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា

## រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស/១៩៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៩៥ អនក្រ/បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល

កម្ពុជាស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា

- យោងតាមការចាំបាច់និងបន្ទាន់ចំពោះមុខ របស់ក្រសួងផែនការ

## សំរេច

**ប្រការ១:** បង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជាហៅកាត់ថា ល.គ.ជ.ស.ជ ដើម្បីជួយការងារដល់គណៈកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា។

**ប្រការ២:** ល.គ.ជ.ស.ជ មានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | អ៊ូ | ឱហាត | ប្រធាន |
| ២- | លោក | នុត | ចន្ទសុខា | អនុប្រធាន |
| ៣- | លោកស្រី | ដួង | សារុន | សមាជិក |
| ៤- | លោក | ហាវ | ឌីណា | សមាជិក |
| ៥- | លោក | ប៉ូ | ម៉ៅ | សមាជិក |
| ៦- | លោក | នុត | សេដ្ឋា | សមាជិក |
| ៧- | លោក | ហួន | ណារ៉ូ | សមាជិក |
| ៨- | លោក | ប៊ុន | ណារិទ្ធ | សមាជិក |

**ប្រការ៣:** ល.គ.ជ.ស.ជ មានភារៈកិច្ច ដូចតទៅ :

- ទំនាក់ទំនង ឬការរៀបចំការប្រជុំអន្តរក្រសួង ស្ថាប័នលើខ្លឹមសារការងារក្នុងក្របខ័ណ្ឌសកម្មភាពអភិវឌ្ឍន៍កម្ពុជា

- សំរបសំរួលការងារតាមរយៈក្រុមការងាររបស់ក្រសួង ស្ថាប័ននិមួយៗ

- ធ្វើការទំនាក់ទំនងនិងសំរបសំរួលជាមួយអង្គការ UNCTAD ដើម្បីរៀបចំឯកសារកម្មវិធីក្នុងក្របខ័ណ្ឌជាតិនៃសកម្មភាពក្នុងការស្តារឡើងវិញ ការកសាង និង អភិវឌ្ឍន៍កម្ពុជាស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដាក់ជូនគណៈកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជាពិនិត្យសំរេច

-ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិរៀបចំកម្មវិធីជាតិនៃសកម្មភាពអភិវឌ្ឍន៍កម្ពុជា

**ប្រការ៤:** ឯកឧត្តម លោក លោកស្រី ដូចមានឈ្មោះនៅក្នុងប្រការ ២ មានភារៈកិច្ចអនុវត្តតាមប្រការនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងផែនការ

**ចម្លងជូន :**

-ទីស្តីការគណៈរដ្ឋមន្ត្រី

- ក្រសួង ស្ថាប័នពាក់ព័ន្ធ

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងផែនការ
លេខ:.....138......ផក.ទទអជ

រាជធានីភ្នំពេញ,ថ្ងៃទី 10 ខែ តុលា ឆ្នាំ ២០០១

# ប្រកាស
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋានសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អនុតំបន់មហាអនុតំបន់ទន្លេមេគង្គ
## រដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/១៩៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ៥៥ អនក្រ/បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ

អាស័យដ្ឋានៈលេខ ៣៨៦ វិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥)២៣ ២១២ ០៩០/៧២០ ៩០១/២១៥ ០៧៣
ទូរសារលេខៈ (៨៥៥)២៣ ២១០ ៩៤៤

- យោងសេចក្ដីសំរេចលេខ ១០ សសរ ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការប្រគល់ភារកិច្ចតាមដាននិងសំរបសំរួលកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់វិសាលភាពទន្លេមេគង្គ
- យោងលិខិតលេខ ៦១០០ អស៊/ កបទ.សអ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០១ របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមការចាំបាច់ និងបន្ទាន់ចំពោះមុខរបស់ក្រសួងផែនការ

## សំរេច

**ប្រការ១:** បង្កើតលេខាធិការដ្ឋានសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់វិសាលភាពទន្លេមេគង្គហៅកាត់ថា លស.អ.ន.ទ.ម ដើម្បីជួយការងារដល់គណៈកម្មាធិការជាតិសំរបសំរួលកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់វិសាលភាពទន្លេមេគង្គ(Greater Mekong Sub-Regional Economic Cooperation ) ។

**ប្រការ២:** លស.អ.ន.ទ.ម មានសមាសភាពដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | អ៊ូ | ឱហាត | ប្រធាន |
| ២- | លោក | នុត | ចន្ទសុខា | អនុប្រធាន |
| ៣- | លោកស្រី | ដួង | សារុន | សមាជិក |
| ៤- | លោក | ឡុង | សោភ័ណ្ឌ | សមាជិក |
| ៥- | លោក | ហាវ | ឌីណា | សមាជិក |
| ៦- | លោកស្រី | ខុន | នារី | សមាជិក |
| ៧- | លោក | នុត | សេដ្ឋា | សមាជិក |
| ៨- | លោក | ហួន | ណារ៉ូ | សមាជិក |
| ៩- | លោក | លន់ | គីមលាង | សមាជិក |
| ១០- | លោក | ស្រី | និមល | សមាជិក |
| ១១- | លោកស្រី | ចាន់ | មាលី | សមាជិក |

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី.....ខែ.....ឆ្នាំ.......

**ប្រការ៣:** ល.អ.ន.ទ.ម មានភារៈកិច្ចដូចតទៅ :

-រៀបចំគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ និងសហប្រតិបត្តិការក្នុងក្របខ័ណ្ឌ GMS ជូនគណៈកម្មាធិការជាតិ ។

- ធ្វើការទំនាក់ទំនងនិងសំរបសំរួលជាមួយធនាគារអភិវឌ្ឍន៍អាស៊ីក្នុងក្របខ័ណ្ឌសហប្រ-តិបត្តិការសេដ្ឋកិច្ចអនុតំបន់វិសាលភាពទន្លេមេគង្គ ។

- ទំនាក់ទំនង ឬការរៀបចំការប្រជុំអន្តរក្រសួង ស្ថាប័នលើខ្លឹមសារការងារក្នុងក្របខ័ណ្ឌមេគង្គ ៦ រៀងរាល់ ០១ខែ ម្តង ។

- សំរបសំរួលការងារតាមរយៈក្រុមការងាររបស់ក្រសួងស្ថាប័ននិមួយៗ

-កសាងគំរោងបណ្តុះបណ្តាលសមត្ថភាពមន្ត្រីជំនាញសំរាប់អនុវត្តគំរោងមេគង្គ ៦ អោយមានប្រសិទ្ធិភាព ។

- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអនុតំបន់វិសាលភាពទន្លេមេគង្គ ពីលទ្ធផលការងារជុំវិញបញ្ហាមេគង្គ ៦ ។

**ប្រការ៤:** ឯកឧត្តម លោក លោកស្រី ដូចមានឈ្មោះនៅក្នុងប្រការ ២ មានភារៈកិច្ចអនុវត្តតាមប្រការនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងផែនការ

**ចម្លងជូន :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធកម្មវិធី GMS
- ស្ថានតំណាងធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំកម្ពុជា
- ឯកសារ-កាលប្បវត្តិ